# រេដបូកដែនជម្រកសត្វព្រៃកែវសីមា

# 2018 – 2019

**ឯកសាររៀបចំដោយៈ អង្គការសមាគមអភិរក្សត្វព្រៃ**







| | |
|---|---|
| **ឈ្មោះគម្រោង** | **គម្រោងកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ដែលបណ្តាលមកពីការបាត់បង់ និងរេចរិលព្រៃឈើនៅក្នុងដែនជម្រកសត្វព្រៃកែវសីមា** |
| **ទីតាំងគម្រោង** | **តំបន់ដែនជម្រកសត្វព្រៃកែវសីមា ខេត្តមណ្ឌលគីរី និងក្រចេះ ព្រះរាជាណាចក្រកម្ពុជា** |
| **ម្ចាស់គម្រោង** | **ក្រសួងបរិស្ថាន រាជរដ្ឋាភិបាលកម្ពុជា**<br>ទំនាក់ទំនង**:** ឯកឧត្តមបណ្ឌិត ជួប ប៉ារីស, អគ្គនាយកនៃនាយកដ្ឋានចំណេះដឹង និងពត៌មានបរិស្ថាន នៃក្រសួងបរិស្ថាន អគារមរតកតេជោ ដីឡូលេខ៥០៣ ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ paris.ncgg@gmail.com, +855 23 213 908 |
| **រយៈពេលគម្រោង** | ការបរិច្ឆេទនៃការចាប់ផ្តើមគម្រោង**:** ១ មករា ២០១០<br>កំឡុងពេលគណនាឧស្ម័នផ្ទះកញ្ចក់ និង រយៈពេលនៃគម្រោង**:** ៦០ ឆ្នាំ |
| **បទដ្ឋាន** CCB | CCBA. 2013. Climate, Community & Biodiversity Standards Third Edition.<br><br>CCBA, Arlington, VA, USA. December, 2013. |
| **ប្រវត្តិនៃការផ្ទៀងផ្ទាត់គម្រោង** | • ទទួលបានការបញ្ជាក់សុពលភាពគម្រោង៖ ១៦ ខែ វិច្ឆិកា ឆ្នាំ២០១៥<br>• ទទួលបានការផ្ទៀងផ្ទាត់លើកទីមួយ ឆ្នាំ ២០១០ ដល់ ឆ្នាំ ២០១៥៖ ០៤ ខែ មេសា ២០១៧<br>• ទទួលបានការផ្ទៀងផ្ទាត់លើកទីពីរ ឆ្នាំ ២០១៦ ដល់ ឆ្នាំ ២០១៧៖ ២៩ ខែ វិច្ឆិកា ២០១៨ |
| **សេចក្តីសង្ខេប** | ទទួលបានការផ្តល់សុពលភាព CCBA ដំបូង (ពេញលេញ)**,** ដោយប្រើស្តង់ដារ CCBA ដែលបានបោះពុម្ពលើកទីបី។<br>**អត្ថប្រយោជន៍អាកាសធាតុ**<br>•គម្រោងនេះត្រូវបានរំពឹងថានឹងមានលទ្ធផលនៅក្នុងការកាត់បន្ថយការបំភាយនៃឧស្ម័នកាបូនិច ១០លានតោន ($tCO_2e$ ១០ លាន**)** ពីការជៀសវាងនូវការបាត់បង់ព្រៃឈើដោយពុំបានរៀបចំគ្រោងទុកជាមុន ក្នុងរយៈពេល ១០ ឆ្នាំខាងមុខ។<br>**អត្ថប្រយោជន៍សហគមន៍**<br>•ការពារតំបន់ព្រៃឈើដែលផ្តល់នូវតម្រូវការជាមូលដ្ឋាន និងអត្តសញ្ញាណវប្បធម៌ ប្រពៃណី ២ ៥០០ គ្រួសារ (ប្រមាណ ១២៥ ០០០ នាក់) នៅក្នុងភូមិដែលចូលរួមក្នុងគម្រោងរេដបូកទាំង ២០ភូមិ។<br>•ពង្រឹងសិទ្ធិកាន់កាប់ និងកាត់បន្ថយភាពគ្មានដីធ្លីរបស់សហគមន៍នៅក្នុងតំបន់ព្រៃសីមាតាមរយ:ការធ្វើផែនការគាំទ្រផ្នែកចុះបញ្ជីកម្មសិទ្ធិដីសហគមន៍ស្របច្បាប់សម្រាប់ជនជាតិដើមភាគតិច **(**ICT**)** ការចូលរួមការធ្វើផែនការប្រើប្រាស់ដីធ្លី (PLUP**)** និងកិច្ចព្រមព្រៀងប្រើប្រាស់ដី។<br>•គាំទ្រការចិញ្ចឹមជីវិតផ្សេងៗ ដែលអាចជួយកាត់បន្ថយការបាត់បង់ព្រៃឈើ ការផ្តល់ឱកាសបង្កើតប្រាក់ចំណូល និងការអភិវឌ្ឍជំនាញ។ នេះរួមបញ្ចូលទាំងអក្ខរកម្ម និងអប់រំសម្រាប់បង្កើនជីវភាពរស់នៅក្រៅពីមុខរបរកសិកម្ម។<br>•ផ្តល់បន្ថែមនូវការផ្សព្វផ្សាយបច្ចេកទេសកសិកម្ម និងការគាំទ្រហេដ្ឋារចនាសម្ព័ន្ធដើម្បីបង្កើននូវសន្តិសុខស្បៀង ប្រាក់ចំណូល និងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ។<br>•ការចែករំលែកផលប្រយោជន៍ដោយផ្តល់នូវប្រាក់ចំណូលពីការលក់កាបូន ក្នុងការគាំទ្រដល់វិស័យអាទិភាពសម្រាប់ការវិនិយោគរបស់សហគមន៍។<br>**អត្ថប្រយោជន៍ជីវចម្រុះ**<br>•ក្នុងកំឡុងពេលដប់ឆ្នាំដំបូងនេះ គម្រោងរេដបូក នឹងទប់ស្កាត់ការបាត់បង់នូវព្រៃអណ្តូមភាគខាងត្បូង និងព្រៃល្បោះទំនាបសម្បូរប្រភេទពពួកឈើទាល (dipterocarp)ជិត ៣០ ០០០ ហិកតា ។ តំបន់គម្រោង ១៦៦ ៩៨៣ ហិកតា គឺជាតំបន់ដ៏ធំបំផុតនៃប្រព័ន្ធអេកូឡូស៊ីដ៏សំខាន់ និងរងការគម្រាមកំហែងទាំងនេះ។<br>•គម្រោងនេះនឹងធានាឱ្យបាននូវភាពធន់ទ្រាំ ជាពិសេសជាទីជម្រកដែលមានមុខងារសម្រាប់ប្រព័ន្ធអេកូឡូស៊ី ដែលរងនូវការរេចរិល និងការរំខានដោយមនុស្ស។ ដូចគ្នានេះដែរ គម្រោងនេះនឹងធានាឱ្យបាននូវភាពធន់ទ្រាំ និងការកើនឡើងវិញនៃប្រភេទសត្វជាច្រើនដែលជាការព្រួយបារម្ភនៃការអភិរក្សជាសកល។ ប្រភេទសត្វដែលគួរឱ្យកត់សម្គាល់មួយចំនួនរួមមានដំរីអាស៊ី ស្វាកន្ទុយស ដែលមានចំនួននៅសល់ធំជាងគេបំផុតនៅលើពិភពលោក ទោចថ្គាល់លឿង ខ្ទីង ទន្សោង និងក្ងោក។<br>**ជីវចម្រុះ កម្រិតមាស**<br>•គម្រោងរេដបូកសីមាមានលក្ខណ:គ្រប់គ្រាន់ដើម្បីទទួលបាននូវបទដ្ឋាន CCB សម្រាប់ជីវចម្រុះកម្រិតមាសសម្រាប់លក្ខណ:វិនិច្ឆ័យដូចខាងក្រោមនេះ:<br>ក. ភាពងាយរងគ្រោះ -ប្រភេទសត្វរងការគំរាមកំហែងចំនួនច្រើនជាង ៥៥ បានបញ្ជាក់ថាប្រភេទសត្វដែលរងការគម្រាមកំហែងនៅទូទាំងពិភពលោកដែលមានវត្តមាននៅក្នុងតំបន់គម្រោង។<br>ខ. ការមិនអាចជំនួស - តំបន់គម្រោងមានចំនួនប្រភេទសត្វជាច្រើន ដែលយ៉ាងហោចណាស់ |

| | |
|---|---|
| | មានចំនួនសត្វ៥ប្រភេទ ដែលមានចំនួនដ៏ច្រើននៃចំនួនសរុបលើពិភពលោកដែលមានវត្តមាននូវដែនជម្រកសត្វព្រៃកែវសីមា ។ |
| **កម្រិតមាស**<br>(Gold Level) | កម្រិតមាសត្រូវបានផ្តល់ឱ្យសម្រាប់ផលប្រយោជន៍ជីវចម្រុះដ៏ប្រសើរ ដោយផ្អែកលើសុចនករនៃភាពរងគ្រោះ នៅពេលដែលគម្រោងផ្តល់នូវផលវិជ្ជមានដ៏សំខាន់ ទៅលើតំបន់ដែលមានគុណតម្លៃសម្រាប់ការអភិរក្ស ដែលរួមបញ្ចូលនូវប្រភេទដែលងាយរងគ្រោះជាលក្ខណ:សាកល។ |
| **រៀបរៀងដោយ** | **អង្គការសមាគមអភិរក្សសត្វព្រៃតំណាងឱ្យក្រសួងបរិស្ថាននៃរាជរដ្ឋាភិបាលកម្ពុជា** |
| **ទំនាក់ទំនង** | **ក្រសួងបរិស្ថាន៖ ឯកឧត្តម បណ្ឌិត ជួប បារីស** (H.E. Dr. Paris Choup)<br>អគ្គនាយកនៃនាយកដ្ឋានចំណេះដឹង និងពត៌មានបរិស្ថាន នៃក្រសួងបរិស្ថាន អគារមរតកតេជោ ដីឡូលេខ៥០៣ ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់<br>សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ paris.ncgg@gmail.com, www.moe.gov.kh<br>**អង្គការសមាគមអភិរក្សត្វព្រៃ:បណ្ឌិត កែន សេរីរដ្ឋា** (Dr. Sereyrotha Ken) sken@wcs.org<br>www.wcscambodia.org |

# មាតិការ

ការសង្ខេបស្តីពីផលប្រយោជន៍គម្រោងរេដបូកកែវសីមា ..... iii
តារាងម៉ាទ្រិចស្តង់ដារស្តីពីផលប្រយោជន៍គម្រោងរេដបូកកែវសីមា ..... iv
១ ទិដ្ឋភាពទូទៅ ..... 8
**១.១ សេចក្តីបរិយាយសង្ខេបអំពីគម្រោង** (G៣) ..... 8
១.២ **ទីតាំងគម្រោង** ..... 9
**១.៤ ម្ចាស់គម្រោង** (G៤) ..... 12
**១.៥ អង្គភាពដទៃទៀតដែលចូលរួមក្នុងគម្រោងនេះ** (G៤) ..... 13
២. ការតាមដាន និងអនុវត្តគម្រោង ..... 14
**២.១. កិច្ចអន្តរាគមន៍ដោយផ្ទាល់** ..... 14
២.២.កិច្ចអន្តរាគមន៍គាំទ្រ ..... 29
៣ស្ថានភាពផ្នែកច្បាប់ ..... 33
**៣.១. ការអនុលោមទៅតាមច្បាប់ និង សិទ្ធិកាន់កាប់ដីធ្លី** ..... 33

## ការសង្ខេបស្តីពីផលប្រយោជន៍គម្រោងរេដបូកកែវសីមា

| លទ្ធផលគម្រោង | សមិទ្ធិផលសម្រេចបានក្នុងកំឡុងពេលតាមដានគម្រោង | ផ្នែកនៃឯកសាយោង | សមិទ្ធិផលសម្រេចបានក្នុងកំឡុងពេលអនុវត្តគម្រោងទាំងមូល |
|---|---|---|---|
| ចំនួននៃការចុះបញ្ជីសម្ហហភាពសហគមន៍ជនជាតិដើមភាគតិចជាផ្លូវការនៅក្នុងតំបន់គម្រោង | ចំនួននៃការចុះបញ្ជីសម្ហហភាពសហគមន៍ជនជាតិដើមភាគតិចចំនួន ៦ ស្ថិតនៅក្នុងដំណើរការ | 2 | សហគមន៍ជនជាតិដើមភាគតិចចំនួន ៧ នៃសហគមន៍ទាំង ១៤ ទទួលបានប័ណ្ណកម្មសិទ្ធិ |
| ចំនួនសហគមន៍ដែលទទួលស្គាល់ដោយក្រសួងបរិស្ថានក្នុងការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ នៅក្នុងតំបន់គម្រោង | ចំនួន មួយសហគមន៍ដែលបានទទួលស្គាល់ដោយក្រសួងបរិស្ថានក្នុងការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ "សហគមន៍តំបន់ការពារធម្មជាតិស្រែព្រះ" | 2 | ចំនួន ១ សហគមន៍តំបន់ការពារធម្មជាតិ ក្នុងចំណោម ៦ សហគមន៍ |

## តារាងម៉ាទ្រិចស្តង់ដារស្តីពីផលប្រយោជន៍គម្រោងរេដបូកកែវសីមា

| ប្រភេទចំណាត់ថ្នាក់ | ម៉ាទ្រិច | សមិទ្ធិផលសម្រេចបានក្នុងកំឡុងពេលតាមដានគម្រោង | ផ្នែកនៃឯកសារយោង | សមិទ្ធិផលសម្រេចបានក្នុងកំឡុងពេលអនុវត្តគម្រោងទាំងមូល |
|---|---|---|---|---|
| ការកាត់បន្ថយការបំភាយ និងស្រូបយកចេញឧស្ម័នផ្ទះកញ្ចក់ | ការកាត់បន្ថយការបំភាយឧស្ម័នតាមរយៈការស្រូបយកចេញដែលបានជាន់ស្មានទៅក្នុងតំបន់គម្រោងដែលវាស់វែងជាមួយសេណារីយ៉ូដែលគ្មានវត្តមានគម្រោង | NA | NA | NA |
| | ការកាត់បន្ថយការបំភាយឧស្ម័នដែលបានជាន់ស្មាននៅក្នុងតំបន់គម្រោងដែលវាស់វែងជាមួយសេណារីយ៉ូដែលគ្មានវត្តមានគម្រោង | 1,641,141 | 3.2 | 16,378,530 |
| គម្របព្រៃឈើ[1] | សម្រាប់គម្រោងរេដបូក[2] : ចំនួនហិកតានៃការបាត់បង់ព្រៃឈើនៅក្នុងតំបន់គម្រោងត្រូវបានវាស់វែងដោយធៀបទៅនឹងសេណារីយ៉ូដែលគ្មានគម្រោង | 2,325 | 3.2 | 21,589 |
| | សម្រាប់ការដាំដុះព្រៃឈើ ការដាំព្រៃឈើឡើងវិញ និងការបង្កើនដំណុះរុក្ខជាតិឡើងវិញ[3] : ចំនួនហិកតានៃគម្របព្រៃឈើដែលកើនឡើងនៅក្នុងតំបន់គម្រោងត្រូវបានវាស់វែងដោយធៀបទៅនឹងសេណារីយ៉ូដែលគ្មានគម្រោង | NA | NA | NA |
| ការធ្វើអោយប្រសើរឡើងនូវការគ្រប់គ្រងដី[2] | ចំនួនហិកតានៃដីព្រៃផ្តល់ផលដែលមានស្រាប់ដែលការអនុវត្តការកែលម្អការគ្រប់គ្រងព្រៃឈើ (IFM)[4] បានធ្វើឡើងដោយសារលទ្ធផលនៃសកម្មភាពរបស់គម្រោងដែលបាន | NA | NA | NA |

[1] ដីដែលជាមួយដុះដោយលទ្ធរុក្ខជាតិ ដែលមាននិយមន័យទទួលស្គាល់ជាអន្តរជាតិ (ដូចជា UNFCCC, FAO ឬ IPCC) នៃអ្វីដែលបង្កើតជាព្រៃដែលរួមបញ្ចូលជាវាំមែត្រដែលមានកត់វិតដូចជា ព្រៃឈើអប្បបរមាកម្ពស់ដើមឈើនិងកម្រិតនៃគម្របកន្សោមស្លឹក ហើយអាចរួមបញ្ចូលទាំងព្រៃចាស់ៗ ព្រៃដុះលូតលាស់ឡើងវិញ ព្រៃរេចរិលនិងព្រៃតំបន់ដីសើម (និយមន័យកម្មវិធី VCS) ។

[2] កាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ចេញពីការបាត់បង់ព្រៃឈើនិងរិចរិលព្រៃឈើ (REDD): សកម្មភាពដែលកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ (GHG) ដោយកាត់បន្ថយឬបញ្ឈប់ការបំលែងពីដីព្រៃទៅជាដីដែលមិនមែនជាព្រៃឬកាត់បន្ថយការរិចរិលនៃដីព្រៃដែលជីវម៉ាស់ព្រៃឈើត្រូវបានបាត់បង់ (និយមន័យកម្មវិធី VCS) ។

[3] ការដាំដុះព្រៃឈើ ការដាំព្រៃឈើឡើងវិញ និងការបង្កើនដំណុះរុក្ខជាតិឡើងវិញ (ARR): សកម្មភាពដែលបង្កើនបរិមាណកាបូននៅក្នុងជីវម៉ាស់ឈើ (និងដីខ្លះ) តាមរយៈការបង្កើត ការបង្កើន និង / ឬការស្តារគម្របរុក្ខជាតិលូតលាស់ឡើងវិញតាមរយៈការដាំដុះ ការសាបនិង / ឬការបង្កើតឡើងវិញដោយដំណុះជាធម្មជាតិតាមការជួយរបស់មនុស្ស (និយមន័យកម្មវិធី VCS) ។

[4] ការកែលម្អការគ្រប់គ្រងព្រៃឈើ (IFM): សកម្មភាពដែលផ្លាស់ប្តូរទំលាប់នៃការគ្រប់គ្រងព្រៃឈើ និងបង្កើនកាបូនលើដីព្រៃឈើសម្រាប់ផលិតផលឈើដូចជា ឈើអា ឈើគៀប និងអុសដុត (និយមន័យកម្មវិធី VCS) ។

| ប្រភេទចំណាត់ថ្នាក់ | ម៉ាទ្រិច | សមិទ្ធិផលសម្រេចបានក្នុងកំឡុងពេលតាមដានគម្រោង | ផ្នែកនៃឯកសារយោង | សមិទ្ធិផលសម្រេចបានក្នុងកំឡុងពេលអនុវត្តគម្រោងទាំងមូល |
|---|---|---|---|---|
| | រស់រវែងជាមួយសេណារីយ៉ូគ្មានគម្រោង | | | |
| | ចំនួនហិកតាដីមិនមែនព្រៃដែលត្រូវបានគ្រប់គ្រងដោយប្រសើរឡើង ជាលទ្ធផលកើតឡើងដោយសារសកម្មភាពរបស់គម្រោងដែលបានរស់រវែងជាមួយសេណារីយ៉ូគ្មានគម្រោង | NA | | NA |
| **ការបណ្តុះបណ្តាល** | ចំនួនសមាជិកសហគមន៍សរុបដែលបានបង្កើនជំនាញនិង / ឬចំណេះដឹងដែលជាលទ្ធផលនៃការបណ្តុះបណ្តាលដែលបានផ្តល់ដែលជាផ្នែកមួយនៃសកម្មភាពគម្រោង | 9,024 | 2 | 21,817 |
| | ចំនួនសមាជិកសហគមន៍ដែលជាស្ត្រី បានបង្កើនជំនាញនិង / ឬចំណេះដឹងដែលជាលទ្ធផលនៃការបណ្តុះបណ្តាលដែលបានផ្តល់ជាផ្នែកមួយនៃសកម្មភាពគម្រោង | 4,558 | 2 | 8,672 |
| **ការងារ** | ចំនួនសរុបនៃមនុស្សដែលបានធ្វើការក្នុងសកម្មភាពគម្រោង[5] ដែលសំដៅទៅលើចំនួនបុគ្គលិកពេញម៉ោង[6] | 207 | 2 | 1,624 |
| | ចំនួនស្ត្រីដែលបានធ្វើការក្នុងសកម្មភាពគម្រោង ដែលសំដៅទៅលើចំនួនបុគ្គលិកពេញម៉ោង | 22 | 2 | 168 |
| **ការបង្កើនជីវភាព** | ចំនួនប្រជាពលរដ្ឋសរុបដែលមានជីវភាព[7] ប្រសើរជាងមុនឬចំណូលដែលបានមកពីសកម្មភាពគម្រោង | 1,096 | 2, 4 | 5,808 |

[5] ការងារនៅក្នុងសកម្មភាពគម្រោងមានន័យថាជាអ្នកធ្វើការងារដោយផ្ទាល់លើសកម្មភាពរបស់គម្រោងដើម្បីទទួលបានប្រាក់សំណង (ហិរញ្ញវត្ថុ ឬអ្វីៗផ្សេងទៀត) រួមទាំងបុគ្គលិក បុគ្គលិកដែលជាប់កិច្ចសន្យា កម្មករដែលបានចុះកិច្ចសន្យានិងសមាជិកសហគមន៍ដែលទទួលបានប្រាក់កម្រៃដើម្បីធ្វើការងារពាក់ព័ន្ធនឹងគម្រោង។

[6] ភាពសមមូលការងារពេញម៉ោងត្រូវបានគេគណនាជាចំនួនសរុបនៃម៉ោងធ្វើការ (ដោយបុគ្គលិកពេញម៉ោង ក្រៅម៉ោង បណ្តោះអាសន្ននិង / ឬតាមរដូវកាល) ដោយចែកដោយចំនួនម៉ោងធ្វើការមធ្យមនៅក្នុងការងារពេញម៉ោងនៅក្នុងប្រទេស និងតំបន់ឬតំបន់សេដ្ឋកិច្ច (អនុលោមទៅតាមប្រព័ន្ធគណនេយ្យរបស់អង្គការសហប្រជាជាតិ (1993) វគ្គ 17.14 [15.102] [17.28]) ។

[7] ជីវភាពរស់នៅគឺជាសមត្ថភាព ទ្រព្យសម្បត្តិ (រួមទាំងទ្រព្យសម្បត្តិនិងធនធានសង្គម) និងសកម្មភាពចាំបាច់សម្រាប់ការរស់ (Krantz, Lasse, 2001. *The Sustainable Livelihood Approach to Poverty Reduction*. SIDA) អត្ថប្រយោជន៍នៃការប្រកបមុខរបរអាចរាប់បញ្ចូលទាំងអត្ថប្រយោជន៍ដែលបានរាយការណ៍នៅក្នុងតារាងម៉ែត្រការងារនៃតារាងនេះ។

| ប្រភេទចំណាត់ថ្នាក់ | ម៉ាទ្រិច | សមិទ្ធិផលសម្រេចបានក្នុងកំឡុងពេលតាមដានគម្រោង | ផ្នែកនៃឯកសារយោង | សមិទ្ធិផលសម្រេចបានក្នុងកំឡុងពេលអនុវត្តគម្រោងទាំងមូល |
|---|---|---|---|---|
| | ចំនួនស្ត្រីដែលមានជីវភាពប្រសើរឡើងឬទទួលបានប្រាក់ចំណូលដែលបានមកពីការធ្វើសកម្មភាពរបស់គម្រោង | 167 | 2, 4 | 1,793 |
| សុខភាព | ចំនួនប្រជាពលរដ្ឋដែលបានទទួលសេវាសុខភាពប្រសើរជាងមុនដោយសារសកម្មភាពរបស់គម្រោងដែលបានត្រូវបានវាស់វែងជាមួយសេណារីយ៉ូគ្មានគម្រោង | 291 | 2 | 3,116 |
| | ចំនួនស្ត្រីដែលបានទទួលសេវាសុខភាពប្រសើរជាងមុនដោយសារសកម្មភាពរបស់គម្រោងដែលបានវាស់វែងជាមួយសេណារីយ៉ូគ្មានគម្រោង | 206 | 2 | 978 |
| ការអប់រំ | ចំនួនសរុបនៃមនុស្សដែលទទួលបានការអប់រំឬគុណភាពនៃការអប់រំត្រូវបានកែលម្អជាលទ្ធផលនៃសកម្មភាពគម្រោងដែលត្រូវបានវាស់វែងជាមួយសេណារីយ៉ូគ្មានគម្រោង | 101 | 4 | 226 |
| | ចំនួនស្ត្រីនិងក្មេងស្រីដែលទទួលបានគុណភាពអប់រំដែលត្រូវបានកែលម្អដោយសារលទ្ធផលនៃគម្រោងដែលត្រូវបានវាស់វែងជាមួយសេណារីយ៉ូគ្មានគម្រោង | 55 | 4 | 133 |
| ទឹក | ចំនួនមនុស្សសរុបដែលទទួលបានការបង្កើនគុណភាពទឹកនិង / ឬបង្កើនលទ្ធភាពទទួលបានទឹកបរិភោគជាលទ្ធផលនៃសកម្មភាពគម្រោងដែលត្រូវបានវាស់វែងជាមួយសេណារីយ៉ូគ្មានគម្រោង។ | 1,200 | 4 | 4,012 |
| | ចំនួនស្ត្រីដែលទទួលបានការបង្កើនគុណភាពទឹកនិង / ឬបង្កើនលទ្ធភាពទទួលបានទឹកផឹកដែលជាលទ្ធផលនៃសកម្មភាពគម្រោងដែលវាស់វែងជាមួយសេណារីយ៉ូគ្មានគម្រោង | 650 | 4 | 1,753 |

| ប្រភេទចំណាត់ថ្នាក់ | ម៉ាទ្រិច | សមិទ្ធិផលសម្រេចបានក្នុងកំឡុងពេលតាមដានគម្រោង | ផ្នែកនៃឯកសារយោង | សមិទ្ធិផលសម្រេចបានក្នុងកំឡុងពេលអនុវត្តគម្រោងទាំងមូល |
|---|---|---|---|---|
| **សុខុមាលភាព** | ចំនួនសមាជិកសហគមន៍សរុបដែលសុខុមាលភាព[8] ត្រូវបានកែលម្អដែលជាលទ្ធផលនៃសកម្មភាពរបស់គម្រោង | 3,523 | 4 | 8,484 |
| | ចំនួនស្ត្រីដែលសុខុមាលភាពរបស់ពួកគេត្រូវបានកែលម្អជាលទ្ធផលនៃសកម្មភាពរបស់គម្រោង | 1,734 | 4 | 5,896 |
| **ការអភិរក្សជីវចម្រុះ** | ការផ្លាស់ប្តូរចំនួនហិកតាដែលគ្រប់គ្រងបានល្អប្រសើរដោយគម្រោងសម្រាប់ការអភិរក្សជីវចំរុះ[9] ដែលវាស់វែងជាមួយសេណារីយ៉ូគ្មានគម្រោង | 187,983 ha | 5.1 | 187,983 ha |
| | ចំនួននៃប្រភេទសត្វដែលជិតផុតពូជឬងាយរងគ្រោះ[10] ដែលត្រូវបានទទួលផលប្រយោជន៍ពីការកាត់បន្ថយការគំរាមកំហែងដែលជាលទ្ធផលនៃសកម្មភាពគម្រោង[11] ដែលវាស់វែងជាមួយសេណារីយ៉ូគ្មានគម្រោង | CR: 9 EN: 25 | 5.1 | CR: 9 EN: 25 |

---

[8] សុខុមាលភាពគឺជាបទពិសោធរបស់ប្រជាជនអំពីគុណភាពនៃជីវិតរបស់ពួកគេ។ ផលប្រយោជន៍ខាងសុខមាលភាពអាចរាប់បញ្ចូលផលប្រយោជន៍ដែលបានរាយការណ៍នៅក្នុងតារាងដទៃទៀតនៃតារាងនេះ (ឧ. ការបណ្តុះបណ្តាលការងារ សុខាភាព អប់រំ ទឹកស្អាតជាដើម) ប៉ុន្តែក៏អាចរួមបញ្ចូលផលប្រយោជន៍ផ្សេងទៀតដូចជា ការផ្តល់សិទ្ធិអំណាចដល់ក្រុមសហគមន៍ ពង្រឹងសិទ្ធិស្របច្បាប់ទៅលើធនធាន, ការអភិរក្សការប្រើប្រាស់នូវតំបន់ដែលមានសំខាន់សម្រាប់វប្បធម៌ ។ល។

[9] ការអភិរក្សជីវចម្រុះនៅក្នុងបរិបទនេះមានន័យថាជាតំបន់ ដែលវិធានការគ្រប់គ្រងជាក់លាក់ត្រូវបានអនុវត្តជាផ្នែកមួយនៃសកម្មភាពគម្រោងដែលមានគោលបំណងលើកកំពស់ការអភិរក្សជីវចម្រុះ។

[10] យោងទៅតាមបញ្ជីក្រហម IUCN នៃប្រភេទដែលត្រូវបានគំរាមកំហែងដោយ ។

[11] ដោយមិនមានវត្តមាននូវការវាស់វែងនូវចំនួន និងវត្តមានរបស់ប្រភេទ រាល់ការវាស់វែងនូវ ការកាត់បន្ថយការគំរាមកំហែងត្រូវបានគេប្រើជាភស្តុតាងនៃផលប្រយោជន៍សម្រាប់ការអភិរក្ស។

# ១ ទិដ្ឋភាពទូទៅ

## ១.១ សេចក្តីបរិយាយសង្ខេបអំពីគម្រោង (G៣)

តំបន់ដែនជម្រកសត្វព្រៃកែវសីមា គ្របដណ្តប់លើផ្ទៃដីទំហំ ២៩២ ៦៩០ហិកតា។ តំបន់នេះស្ថិតនៅភាគខាងកើតប្រទេសកម្ពុជា ដែលភាគច្រើនស្ថិតក្នុងខេត្ត មណ្ឌលគិរី និង មានមួយផ្នែកតូចស្ថិតក្នុងខេត្តក្រចេះ។ គម្រោងកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ដែលបណ្តាលមកពីការបាត់បង់ព្រៃឈើ និង ការរេចរិលនៃព្រៃឈើ **(REDD+)** គ្របដណ្តប់លើផ្ទៃដីព្រៃទំហំ ១៦៦ ៩៨៣ ហិកតា ដែលស្ថិតនៅក្នុងតំបន់ការពារស្នូលរបស់តំបន់ដែនជម្រកសត្វព្រៃកែវសីមា។ នៅចុងឆ្នាំ២០០៩ តំបន់ការពារនេះ ត្រូវបានបង្កើតឡើង ដោយអនុក្រឹត្យ របស់នាយករដ្ឋមន្ត្រី ជា"តំបន់ព្រៃការពារសីមា"។ ដំណើរការនេះ បានលើកកម្ពស់ ស្ថានភាពអភិរក្សអតីតតំបន់អភិរក្សជីវចម្រុះសីមា ដែលបានដំណើរការនៅក្នុងអំឡុងឆ្នាំ ២០០២-២០០៩។ មកដល់ឆ្នាំ ២០១៦ តំបន់ព្រៃការពារសីមា ត្រូវបានចាត់ថ្នាក់ឡើងវិញ ដោយរាជរដ្ឋាភិបាលកម្ពុជាជា"តំបន់ដែនជម្រកសត្វព្រៃ កែវសីមា" ក្រោមអនុក្រឹត្យលេខ ៨៣ ចុះថ្ងៃទី ០៩ ខែឧសភា ឆ្នាំ២០១៦ និងស្ថិតក្នុងការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន។ ទីតាំងនេះ គឺជាផ្នែកមួយនៃទឹកដីកំណើតតាំងពីដូនតារបស់ជនជាតិ ដើមភាគតិចព្នងយ៉ាងច្រើន ហើយសម្រាប់ពួកគាត់ ព្រៃឈើ គឺជាប្រភពប្រាក់ចំណូលដ៏សំខាន់ និងជាស្នូល នៃជំនឿរបស់ពួកគាត់ទៅលើព្រលឹង។ មិនតែប៉ុណ្ណោះ តំបន់នេះ គឺជាទីប្រជុំតំបន់បរិស្ថាន ដ៏សំខាន់ចំនួនពីរពោលគឺជួរភ្នំអាណាម(ដែលគួរឱ្យកត់សម្គាល់ទៅលើលក្ខណៈខុសប្លែកពីគេយ៉ាងខ្លាំងនៅមូលដ្ឋាន ក្នុងចំណោមប្រភេទព្រៃស្រោង រឺ បៃតងគ្រប់រដូវកាល) និងព្រៃ ល្បោះស្ងួតនៅតំបន់ទន្លេមេគង្គក្រោម (ដែលមានសារសំខាន់បំផុតសម្រាប់ការរស់រាន របស់រុក្ខជាតិជាច្រើនប្រភេទ ដែលមានលក្ខណៈជា ព្រៃជ្រុះស្លឹកប្រចាំឆ្នាំនៅតាមតំបន់ដីទំនាប)។ មានសត្វមានឆ្អឹងខ្នងចំនួន ៥៥ប្រភេទ ដែលទទួលរងការគម្រាមកំហែងទូទាំងសាកលលោក ដែលត្រូវបានរកឃើញនៅក្នុងតំបន់គម្រោងនេះ (ក្នុងនោះ ៩ប្រភេទ ប្រឈមនឹងការផុតពូជខ្លាំងបំផុត និង២៥ប្រភេទប្រឈមនឹងការផុតពូជ)។ ភាគច្រើននៃប្រភេទ សត្វទាំងនេះស្ថិតក្នុងចំនួនមួយដែលត្រូវយកចិត្តទុកដាក់ជាសាកល ឬ នៅថ្នាក់តំបន់ដែល រួមមានដំរីអាស៊ី អម្បូរស្វា អម្បូរគោព្រៃ អម្បូរម៉ំសាសី និង បក្សី ដូចជា ត្រយ៉ងយក្ស និង ក្ងោក។

ក្នុងពេលបច្ចុប្បន្ននេះតំបន់ដែនជម្រកសត្វព្រៃកែវសីមា ស្ថិតក្រោមការគំរាមកំហែងពីការកើនឡើងនូវការកាប់រានព្រៃសម្រាប់ធ្វើកសិកម្មស្របគ្នានឹងការទាញយកធនធាន ដែលគ្មាននិរន្តរភាព (ដូចជា ការបរបាញ់សត្វ ការកាប់ឈើ)។ សកម្មភាពទាំងនេះធ្វើឱ្យប៉ះពាល់ ទាំងទៅលើជីវចម្រុះ និងការប្រកបរបរចិញ្ចឹមជីវិតដែលពឹងផ្អែកទៅលើព្រៃឈើក្នុងមូលដ្ឋាន។ កត្តាជំរុញការគម្រាមកំហែងដោយផ្ទាល់ក្នុងពេលបច្ចុប្បន្ននេះមានដូចជា កំណើននៃការប្រើប្រាស់ផ្លូវថ្នល់ កំណើនប្រជាជនក្របខ័ណ្ឌអនុវត្តច្បាប់ និង អភិបាលកិច្ចមានភាពទន់ខ្សោយ ការមិនសូវយល់ដឹងពីគុណតម្លៃរបស់ជីវចម្រុះ សេវាកម្មផ្នែកបរិស្ថាន និង កំណើនតម្រូវការទីផ្សារ ទាំងទៅលើផលិតផលពីព្រៃ និង ផលិតផលកសិកម្ម។ ការអភិវឌ្ឍធនធានរ៉ែ និងដំណាំកសិឧស្សាហកម្មក៏អាចក្លាយជាកត្តាបំផ្លិចបំផ្លាញព្រៃឈើក្នុងពេលអនាគតដ៏មានសក្តានុពលផងដែរ ប្រសិនបើរដ្ឋាភិបាលមិនបានការពារតំបន់នោះយ៉ាងពេញលេញទេ។ ការប្រមូលផលប្រភេទឈើប្រណិតកម្រដោយខុសច្បាប់គឺទាក់ទងនឹងកិច្ចការអនុវត្តច្បាប់ដ៏តឹងរឹងនៅក្នុងទីតាំងនោះ ក៏ដូចជានៅតាមកន្លែងផ្សេងទៀតនៅក្នុងប្រទេសកម្ពុជាដែរ ក៏ប៉ុន្តែវាមានឥទ្ធិពលតិចតួច ក្នុងរយៈពេលវែងទៅលើការស្តុកទុកកាបូន។

ចាប់តាំងពីឆ្នាំ២០០២មក រដ្ឋបាលព្រៃឈើបានសហការជាមួយនឹងអង្គការអភិរក្សសត្វព្រៃ (WCS) និងដៃគូអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយចំនួនទៀតដើម្បីបង្កើតប្រព័ន្ធគ្រប់គ្រងតំបន់ដែនជម្រកសត្វព្រៃកែវសីមា សម្រាប់ថែរក្សា និងស្តារតម្លៃជីវចម្រុះ ព្រមទាំងការពារមុខរបររបស់ប្រជាជនមូលដ្ឋានផងដែរ។ គម្រោងអភិរក្សនេះមានវិធីសាស្ត្រគ្រប់ជ្រុងជ្រោយមួយ ដែលមានអន្តរាគមន៍ផ្ទាល់ចំនួន៤៖ ការពង្រឹងយន្តការច្បាប់ និង ការគាំទ្រផ្នែកគោលនយោបាយ ការអនុវត្តច្បាប់ដោយផ្ទាល់ការពង្រឹងការគ្រប់គ្រងធនធានធម្មជាតិក្នុងសហគមន៍ និងការបង្កើតមុខរបរជំនួស។ ការអនុវត្ត

ច្បាប់ប្រកបដោយប្រសិទ្ធភាពមានសារសំខាន់ខ្លាំងណាស់ ព្រោះវាជួយគាំទ្រដល់គ្រប់សកម្មភាពការងារផ្សេងទៀត ។ ការរួមចំណែកប្រកបដោយនិរន្តរភាពក្នុងការគាំទ្រដល់ការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីសម្ហូហភាពជូនសហគមន៍ជនជាតិដើមភាគតិចទាំងអស់នៅក្នុងតំបន់នោះ មានលក្ខណៈគួរឱ្យ កត់ សម្គាល់បំផុត ពីព្រោះវាការពារមុខរបរ និង សិទ្ធិកាន់កាប់ដីធ្លីរបស់ពួកគាត់ ហើយទន្ទឹមគ្នានោះបង្កើតបានជាមូលដ្ឋានរឹងមាំមួយសម្រាប់សហការគ្នាអនុវត្តគម្រោងនេះ។

ការអន្តរាគមដើម្បីអភិរក្សនៅមុនពេលអនុវត្តគម្រោងរេដ គឺនៅមានកម្រិតតិចតួចនៅឡើយ។ សកម្មភាពអនុវត្តច្បាប់ទទួលបានជោគជ័យក្នុងការកាត់បន្ថយ (ក៏ប៉ុន្តែមិនបានទប់ស្កាត់) ការគម្រាមកំហែងធំៗនៅគ្រប់ផ្នែករបស់តំបន់ដែនជម្រកសត្វព្រៃកែសីមា ដោយបានកាត់បន្ថយអត្រាកាប់បំផ្លាញព្រៃឈើ និង បានជួយឱ្យប្រភេទសត្វព្រៃសំខាន់ៗមួយចំនួននៅគង់វង្សក្នុងចំនួនច្រើន។ ការអន្តរាគមក្នុងកម្រិតតិចតួចនេះត្រូវបានសន្និដ្ឋានថានឹងបន្ត ធ្វើជាផ្នែកមួយនៃគម្រោងមូលដ្ឋានក្នុងពេលអនាគត។ ទោះបីជាបែបណាក្តី អន្តរាគមន៍នេះស្ថិតនៅក្រោមកម្រិតមួយដែលចង់បាន ដើម្បីឆ្លើយតបទៅនឹងទ្រង់ទ្រាយនៃការគម្រាមកំហែងទាំងឡាយ។ ការគម្រាមកំហែងភាគច្រើននៅតែមានកម្រិតធ្ងន់ធ្ងរនៅឡើយ ហើយកំពុងបន្តកើនឡើងទាំងទ្រង់ទ្រាយ និង ប្រភេទខុសៗគ្នា។ អត្រាកាប់ឈើ និង កាប់បំផ្លាញព្រៃឈើបានកើនឡើង ដោយក្នុងនោះយ៉ាងហោចណាស់មានសត្វដ៏សំខាន់មួយប្រភេទ (ខ្លា) បានធ្វើឱ្យបាត់បង់ពីចំនួនដែលបម្រុងទុក ហើយរំពឹងថានឹងមានការថយចុះបែបនេះសម្រាប់ ប្រភេទសត្វដទៃទៀត។ ការកំណត់ព្រំប្រទល់ ការយាមល្បាតប្រកបដោយប្រសិទ្ធភាព ការចុះអប់រំតាមសហគមន៍ សកម្មភាពប្រកបមុខរបរផ្សេងពីមុនជាដើម ត្រូវបានអនុវត្តតែ ទៅលើមួយផ្នែកធំនៃព្រៃបម្រុងនោះប៉ុណ្ណោះ។ ប្រសិទ្ធភាពក្នុងការគ្រប់គ្រង ការអភិរក្ស ត្រូវបានរារាំងយ៉ាងខ្លាំង ដោយសារតែ ការផ្តល់មូលនិធិមិនបានគ្រប់គ្រាន់ មិនទៀងទាត់ និង បន្តធ្លាក់ចុះ ព្រមគ្នាជាមួយនឹងការដណ្តើមប្រើប្រាស់ដីធ្លី។ ហេតុដូច្នេះ ហើយការផ្តល់ហិរញ្ញប្បទានប្រកបដោយនិរន្តរភាពតាមរយៈប្រាក់ចំណូលពីការលក់កាបូន មានសារសំខាន់ណាស់សម្រាប់សម្រួលដល់ការពង្រីក និង ការទ្រទ្រង់សកម្មភាពអភិរក្សសម្រាប់រយៈពេលវែង។ កត្តានេះនឹងជួយដល់រាជរដ្ឋាភិបាលកម្ពុជា និង ដៃគូអង្គការមិនមែនរដ្ឋាភិបាលរបស់ខ្លួនក្នុងការពង្រីកសកម្មភាពបន្ថែមទៀត ដើម្បីឆ្លើយតបទៅនឹងកម្រិតនៃការគំរាមកំហែងជានាការគាំទ្រសម្រាប់រយៈពេលវែងតាមរយៈការរ៉ាប់រងលើការចំណាយប្រតិបត្តិការ និង ផ្តល់រង្វាន់លើកទឹកចិត្តជាថវិកាសម្រាប់ការអភិរក្សនៅថ្នាក់មូលដ្ឋាន និង ថ្នាក់ជាតិ។

គម្រោងនេះទទួលបានប្រយោជន៍ពីការគាំទ្រដ៏ខ្លាំងក្លា និងប្រកបដោយនិរន្តរភាពពីម្ចាស់ជំនួយ និង ផ្នែកនយោបាយ ដៃគូអង្គការមិនមែនរដ្ឋាភិបាលដែលមានទស្សនៈបើកចំហ រួមសហការ មានស្ថេរភាព និង មានរយៈពេលវែង វត្តមានបុគ្គលកាន់មុខតំណែងជាអ្នកដឹកនាំដែលមានការប្តេជ្ញាចិត្តខ្ពស់ ការទទួលស្គាល់ថា ការអនុវត្តច្បាប់ប្រកបដោយប្រសិទ្ធភាព និង សមធម៌ គឺជាមូលដ្ឋានគ្រឹះសម្រាប់រាល់អន្តរាគមន៍ផ្សេងទៀត និង ឆន្ទៈក្នុងការអនុវត្តបច្ចេកទេសថ្មីៗ។ ការអនុវត្តសាកល្បងនូវបច្ចេកទេសមួយចំនួនចាប់តាំងពីឆ្នាំ ២០០២មក កំណត់បាននូវវិធីសាស្ត្រជោគជ័យមួយចំនួនក្នុងការដោះស្រាយបញ្ហាប្រឈមសំខាន់ៗមួយចំនួនធំដែលបានជួបប្រទះហើយបូករួមនឹងហិរញ្ញប្បទានគ្រប់គ្រាន់ ការគ្រប់គ្រងដ៏ពេញលេញ និង មានប្រសិទ្ធភាពអាចដំណើរការទៅបាន។

ការបរិយាយជាលម្អិតអំពីគោលដៅ និងសកម្មភាពដែលបានអនុវត្តកន្លងចាប់ពីឆ្នាំ ២០១៨ ដល់ ២០១៩ មករបស់គម្រោងនេះ នឹងត្រូវបានបរិយាយនៅក្នុងរបាយការណ៍។

គម្រោងនេះមានគោលបំណងសម្រេចបាននូវការផ្តល់សុពលភាពរួមផ្សៀបទៅនឹង ប្រព័ន្ធ ផ្តល់វិញ្ញាបនបត្របញ្ជាក់កាបូន (VCS) និង បទដ្ឋានសម្ព័ន្ធអាកាសធាតុ សហគមន៍ និង ជីវចម្រុះ (CCBA)។

## ១.២ ទីតាំងគម្រោង

គម្រោងនេះត្រូវបានធ្វើឡើងស្ទើរតែទាំងស្រុងនៅក្នុងដែនជម្រកសត្វព្រៃកែវសីមា ដែលភាគច្រើនស្ថិតនៅខេត្តមណ្ឌលគិរីដោយមានផ្នែកមួយចំនួនដែលលាតសន្ធឹងក្នុងខេត្ត ក្រចេះ។ តំបន់នេះមានព្រំប្រទល់ជាប់នឹងប្រទេសវៀតណាមដែលខណ្ឌចែកដោយផ្លូវជាតិលេខ

៧៦។ ទីស្នាក់ការកណ្ដាលរបស់ដែនជម្រកសត្វព្រៃកែវសីមា ស្ថិតនៅភាគនិរតីនៅក្នុងស្រុកកែវសីមានៅចំណុចលេខ **106 ° 55'15.7 "**E, **12 ° 8'13.109"** N ។

វិធីសាស្រ្តទាមទារនិយមន័យនៃតំបន់គ្រប់គ្រងដែលមិនត្រួតស៊ីគ្នាជាច្រើនដូចដែលបានរៀបរាប់លម្អិត សង្ខេបនៅទីនេះ។ តំបន់គម្រោង (ដែលជាតំបន់ដែលឥណទាននឹងត្រូវបានបង្កើតឡើង) រួមមាន តំបន់ព្រៃការពារស្នូល (ដូចបានកំណត់ក្នុងអនុក្រឹត្យលេខ ១៤៣ ឆ្នាំ ២០០៩) ជាតំបន់ព្រៃ តំបន់លេចធ្លាយ/ទ្រនាប់ដែលព័ទ្ធជុំវិញនិងនៅជាប់តំបន់ព្រៃស្នូល ដែលតំបន់នេះអាចប្រឈមនឹងបាត់បង់ព្រៃឈើមួយចំនួន។ តំបន់គ្រប់គ្រងតំបន់លេចធ្លាយ ត្រូវបានជ្រើសរើស នៅតំបន់ដែលអាចនឹងមានសកម្មភាពកែលម្អជីវភាព តំបន់មិនមែនព្រៃឈើ និងតំបន់កសិកម្មដែលត្រូវបានប្រើប្រាស់ដោយអ្នកភូមិដែលចូលរួមក្នុងគម្រោង។ តំបន់ទាំងបីនេះគឺជាមូលដ្ឋាននៃតំបន់គម្រោងដែលត្រូវបានកំណត់តាមស្តង់ដារ CCB ។ រូបភាពទី **1** បង្ហាញពីទិដ្ឋភាពទូទៅនៃទីតាំងនៃតំបន់គម្រោង។

រូបទី **1** ដែនជម្រកសត្វព្រៃកែវសីមា




**ស្ថានភាពដី**(Topography)
ដែនជម្រកសត្វព្រៃកែវសីមា និងតំបន់ជុំវិញរបស់វាបង្កើតជាសណ្ឋានដីដែលមានសណ្ឋានដីចាប់ពី 60-750 ម៉ែត្រ។ ផ្នែកខាងក្រោមនៅភាគខាងជើង និងខាងលិចនៃតំបន់គម្រោងគឺស្ថិតនៅតំបន់វាលទំនាបភាគខាងកើត។ នៅខាងកើតតំបន់នេះបានកើនឡើងនៅលើកំពស់ទៅខ្ពង់រាបសែនមនោរម្យដែលបង្កើតជាតំបន់ភាគនិរតីនៃជួរភ្នំអាណាម ដែលជាចំណុចកណ្តាលមួយក្នុងចំណោមចំណុចកណ្តាលជីវសម្បូរទៅដោយប្រភេទសត្វព្រៃនៃតំបន់អាស៊ី។

**ដី**

ដីមានបរិមាណដ៏មានសក្តានុពលខ្ពស់ទៅលើថ្មដែលចំណាស់ ជាលក្ខណៈខ្ពង់រាប ដែលដីទំនាបភាគច្រើនមានកម្រិតទាបទៅមធ្យម លើកលែងតែតំបន់ដីល្បប់នៅតំបន់មួយចំនួន។

**ជលសាស្ត្រ**

ដៃទន្លេទំហំមធ្យមពីរនៅតាមដងទន្លេមេគង្គបានបង្ហូរភាគច្រើននៃតំបន់នេះ ខណៈដែលជ្រលងភ្នំភាគខាងត្បូងលិចចូលក្នុងប្រព័ន្ធស្ទឹងដាយណៃ (Dai Nang) នៅវៀតណាម។ ទន្លេភាគច្រើនឈប់ហូរក្នុងរដូវប្រាំងដែលមានរយៈភាពយូរ។ វាលទំនាបត្រូវបានសម្គាល់ដោយតំបន់ដីសើមតូចៗសម្បូរទៅដោយស្មៅ និងត្រពាំងនៅតាមព្រៃ។

**អាកាសធាតុ**

អាកាសធាតុគឺតំបន់ត្រូពិចខ្យល់មូសុង: រដូវប្រាំងចាប់ពីខែវិច្ឆិកាដល់ខែមេសាជាមួយខ្យល់បក់ពីទិសខាងជើង និងរដូវវស្សាចាប់ពីខែឧសភាដល់ខែតុលាជាមួយខ្យល់បក់ពីខាងត្បូង ។ បរិមាណទឹកភ្លៀងប្រចាំឆ្នាំសរុបគឺ 2200-2800 មម នៅទីស្នាក់ការកណ្តាលដែនជម្រកសត្វព្រៃកែវសីមា ជាចំនុចខ្ពស់ជាងគេនៅលើខ្ពង់រាប និងក៏ប្រហែលជាមានតំបន់ទំនាបទាបជាងគេផងដែរ ។ ភ្លៀងជាង 85% នៅទីស្នាក់ការកណ្តាលស្ថិតនៅក្នុងកំឡុងខែឧសភា - ខែតុលា។ ចាប់ពីខែធ្នូដល់ខែមេសាជាទូទៅមានកំពស់តិចជាង 100 មម ក្នុងមួយខែ ហើយតាមធម្មតារដូវប្រាំងមានរយៈពេល ៥ ខែ ។

១.៣ សហគមន៍ដែលចូលរួម

មានភូមិចំនួន ២០ ដែលងាយនឹងទទួលរងផលប៉ះពាល់ពីគម្រោងនេះ ហើយភូមិទាំងនោះត្រូវបានកំណត់ថាជា ភូមិដែលចូលរួម។ គម្រោងរួមបញ្ចូល ភូមិសំខាន់ៗ ចំនួន ១៧ (ដែលមានដីធ្វើកសិកម្ម ឬ ដីលំនៅឋាននៅក្នុងតំបន់ការពារស្នូល) និង ភូមិអ្នកប្រើប្រាស់ចំនួន ៣ ផ្សេងទៀត (ដែលបានបញ្ជាក់ថាមានការប្រើប្រាស់ព្រៃឈើ ជាទៀងទាត់ និងក្នុងបរិមាណច្រើននៅក្នុងតំបន់ការពារស្នូល ក៏ប៉ុន្តែមិនមានដីធ្វើកសិកម្ម ឬ ដីលំនៅឋាននៅក្នុងនោះទេ)។

តារាង ១.១ និង រូបទី២ បរិយាយសង្ខេបអំពីអង្គភាពរដ្ឋបាលដែលពាក់ព័ន្ធក្នុងគម្រោងនេះ។ ក្រុមប្រឹក្សាឃុំ គឺជាអង្គភាពជាប់ឆ្នោតថ្នាក់ក្រោមបង្អស់នៅក្នុងរដ្ឋាភិបាលកម្ពុជា ហើយប្រធានភូមិត្រូវបានតែងតាំងដោយក្រសួងមហាផ្ទៃ។ ការស្ទង់មតិមួយចំនួនបានរកឃើញថាមានភូមិចំនួន ២០ ដែលងាយនឹងទទួលរងផលប៉ះពាល់ពីគម្រោងនេះ ហើយភូមិទាំងនោះត្រូវបានកំណត់ថាជា ***ភូមិដែលចូលរួម*។**

តារាង ១.១ ៖ អង្គភាពរដ្ឋបាលដែលពាក់ព័ន្ធក្នុងគម្រោង

| ខេត្ត | ស្រុក | ឃុំ | ភូមិសំខាន់ | ភូមិអ្នកប្រើប្រាស់ដទៃទៀត |
|---|---|---|---|---|
| មណ្ឌលគិរី | កែវសីមា | ស្រែខ្ទុម | អូររអាម អូររណារ ស្រែល្វី | |
| | | ស្រែព្រះ | ស្រែព្រះ ហ្គាទី ពូចារ អូប្រារ ពូគង់ | |
| | | ស្រែឈូក | ចក់ចារ ក្លូម ស្រែអណ្តោល ស្រែខ្ទង់ | |
| | | មេម៉ង់ | ពូគេះ ពូដោល | |
| | អូរាំង | សែនមនោរម្យ | អណ្តូងក្រឡឹង ពូហ្យាម ពូរាំង | |
| | សែនមនោរម្យ | រមនា | | ស្រែ អ៊ី ពូត្រុំ ពូតាំង |

**ផែនទីភូមិប្រើប្រាស់ដីក្នុងតំបន់អនុវត្តគម្រោង "រេដ" នៃតំបន់ព្រៃការពារ និងអភិរក្សជីវចម្រុះ "សីមា" ខេត្តមណ្ឌលគិរី និងខេត្តក្រចេះ**




រូបទី 2 ភូមិដែលចូលរួមនៅក្នុងតំបន់ព្រៃការពារសីមា របស់គម្រោងរេដ

## ១.៤ ម្ចាស់គម្រោង (G៤)

ម្ចាស់គម្រោងនេះ គឺរាជរដ្ឋាភិបាលកម្ពុជា ដែលតំណាងដោយក្រសួងបរិស្ថាន។ ក្រសួងបរិស្ថាន ទទួលខុសត្រូវក្នុងការគ្រប់គ្រងទីតាំងនេះ ដោយមានតួនាទីដូចខាងក្រោម ឬលើសពីនេះ៖

- ការចាត់តាំងបុគ្គលិក រួមមានប្រធានគ្រប់គ្រងតំបន់ការពារ ឬ អ្នកដែលមានតំណែងស្មើ
- ការបង្កើតផែនការងារ និង កញ្ចប់ថវិកា
- ការអនុវត្តសកម្មភាពទាំងឡាយ ដូចជា ការអនុវត្តច្បាប់ ការងារសហគមន៍ និង ការកំណត់ព្រំប្រទល់
- ការតាមដានមើលការចូលរួមរបស់ភ្នាក់ងារដទៃទៀតនៅក្នុងរដ្ឋាភិបាល ដូចជា កងកម្លាំងប្រដាប់អាវុធ ជាដើម
- ការសម្របសម្រួលជាមួយនឹងស្ថាប័នចំណុះរដ្ឋាភិបាល
- ការតាមដានមើលការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាល

ពាក់ព័ន្ធនឹងគម្រោងកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ ដែលបណ្តាលមកពីការបាត់បង់ព្រៃឈើ និង ការរេចរិលនៃព្រៃឈើក្រសួងបរិស្ថានទទួលខុសត្រូវដូចខាងក្រោម ៖

- ការត្រួតពិនិត្យ និង ការគ្រប់គ្រងជារួម (រួមទាំងក្របខ័ណ្ឌបែងចែកផលប្រយោជន៍ និង ការសម្របសម្រួលដៃគូចូលរួមផងដែរ)
- ការចាត់តាំងបុគ្គលិកសំខាន់ៗ រួមមាន ប្រធានក្រុមការងារ និង អ្នកគ្រប់គ្រង
- ការអនុម័តទៅលើការអភិវឌ្ឍគម្រោងផែនការការងារ និង របាយការណ៍ត្រួតពិនិត្យ
- ការអនុវត្តសកម្មភាពមួយចំនួននៅក្នុងផែនការការងារដែលក្រសួងបរិស្ថានទទួលខុសត្រូវ

- ការសម្របសម្រួលការងាររបស់គម្រោងរេដពាក់ព័ន្ធនឹងទិដ្ឋភាពគ្រប់គ្រងតំបន់ដែនជម្រកសត្វព្រៃកែវសីមា

| **ក្រសួងបរិស្ថាន នៃរាជរដ្ឋាភិបាលកម្ពុជា** | |
|---|---|
| **ទំនាក់ទំនង៖** | **ឯឧត្តម បណ្ឌិត ជួប ប៉ារីស** |
| **តួនាទី៖** | **អគ្គនាយកនៃនាយកដ្ឋានចំណេះដឹង និងពត៌មានបរិស្ថាន នៃក្រសួងបរិស្ថាន** |
| **អាស្រ័យដ្ឋាន៖** | **អគារមរតកតេជោ ដីឡូលេខ៥០៣ ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ កម្ពុជា** |
| **ទូរស័ព្ទ៖** | +855 23 213 908 |
| **អ៊ីម៉ែល៖** | paris.ncgg@gmail.com |
| **គេហទំព័រ៖** | www.moe.gov.kh |

## ១.៥ អង្គភាពដទៃទៀតដែលចូលរួមក្នុងគម្រោងនេះ (G៤)

អង្គការសមាគមអភិរក្សសត្វព្រៃ ដែលមានកម្មវិធីនៅក្នុងប្រទេសកម្ពុជា គឺជាដៃគូរបច្ចេកទេសឈានមុខគេ។ អង្គការសមាគមអភិរក្សសត្វព្រៃបានសហការជាមួយនឹងរដ្ឋបាលព្រៃឈើនៅក្នុងទីតាំងនេះចាប់តាំងពីការស្ទង់មតិអំពីសត្វព្រៃលើកដំបូងក្នុងឆ្នាំ ២០០០ មកម្លេះ។ អង្គការសមាគមអភិរក្សសត្វព្រៃក៏បានសហការជាមួយក្រសួងបរិស្ថាន តាំងពីឆ្នាំ២០០០ តាមរយៈ សហគ្រប់គ្រងតំបន់ការពារ នៃគម្រោងការអភិរក្សព្រៃកទាល់ និងតំបន់ដែនជម្រកសត្វព្រៃ គូលែនព្រហ្មទេព។ អង្គការសមាគមអភិរក្សសត្វព្រៃធ្វើការ លើគម្រោងរេដបូក ក្រោមអាណត្តិនៃកិច្ចព្រមព្រៀងបន្តគម្រោង ៣ឆ្នាំម្តង ជាមួយនឹងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ។ កិច្ចព្រមព្រៀងដែលបន្ត ៣ឆ្នាំម្តងៗជាបន្តបន្ទាប់បានធ្វើឡើងចាប់តាំងពីឆ្នាំ១៩៩៩ ជាមួយនឹងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ហើយនឹងបន្តរហូតជាមួយក្រសួងបរិស្ថានដល់ពេលអនាគត ។ ប្រសិនបើកិច្ចព្រមព្រៀងនេះត្រូវបានបញ្ចប់ដោយផ្អែកលើឆន្ទានុសិទ្ធិរបស់ភាគីណាមួយនោះ ក្រសួងបរិស្ថាននឹងទទួលខុសត្រូវក្នុងការចុះកិច្ចព្រមព្រៀងដទៃទៀត ដើម្បីបំពេញតួនាទីរបស់ អង្គការសមាគមអភិរក្សសត្វព្រៃក្នុងការអនុវត្តសកម្មភាពទាំងឡាយក្នុងគម្រោងរេដបូក។

ស្ថិតក្នុងវិសាលភាពដែលអាចធ្វើបានផ្អែកលើថវិកា និង ធនធានដែលមាន អង្គការសមាគមអភិរក្សសត្វព្រៃទទួលខុសត្រូវដូចខាងក្រោម ៖

- ផ្តល់ដំបូន្មានផ្នែកបច្ចេកទេសទៅលើគ្រប់ទិដ្ឋភាពនៃការអភិរក្សនៅនឹងទីតាំងផ្ទាល់
- ជួយធ្វើសេចក្តីព្រាងឯកសារគម្រោងមួយចំនួន ដូចជា ឯកសារអភិវឌ្ឍន៍គម្រោង របាយការណ៍ប្រចាំឆ្នាំ និង របាយការណ៍ផ្ទៀងផ្ទាត់
- គ្រប់គ្រងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលរបស់ខ្លួនផ្ទាល់ដែលចូលរួមនៅក្នុងគម្រោង
- សម្របសម្រួលការចូលរួមចំណែករបស់អង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការផ្នែកអភិវឌ្ឍន៍/មុខរបរចិញ្ចឹមជីវិត
- រួមសហការដើម្បីរក្សាស្ថេរភាពថវិកាក្រៅគម្រោងរេដបូក ដែលត្រូវការសម្រាប់អាជីវកម្មដែលជាសកម្មភាពធម្មតា។

ដៃគូអនុវត្តសំខាន់ៗដទៃទៀត គឺជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និង អន្តរជាតិដែលធ្វើការផ្នែកអភិវឌ្ឍន៍។ ដៃគូជាក់លាក់នឹងអាស្រ័យទៅលើកម្រិតថវិកា និង តម្រូវការបច្ចេកទេសរបស់គម្រោង ហើយអាចនឹងមានការប្រែប្រួលនៅក្នុងអំឡុងពេលអនុវត្តនូវគម្រោងនេះដោយផ្អែកលើមូលដ្ឋាននៃកិច្ចសន្យាដែលបានពិភាក្សាដើម្បីផ្តល់សេវានានា។ ដៃគូចម្បងក្នុងរយៈពេលប៉ុន្មានឆ្នាំនៅដើមគម្រោងនេះ គឺក្រុមអភិវឌ្ឍន៍ជនបទកម្ពុជា (CRDT)។ ក្រុមអភិវឌ្ឍន៍ជនបទកម្ពុជាបានសហការជាមួយនឹងរដ្ឋបាលព្រៃឈើ និង អង្គការសមាគមអភិរក្សសត្វព្រៃនៅក្នុងទីតាំងគម្រោងចាប់តាំងពីឆ្នាំ២០០៥មកម្លេះ ហើយនៅក្នុងអំឡុងឆ្នាំ២០០៨-២០១០ ក្រុមអភិវឌ្ឍន៍ជនបទកម្ពុជាបានធ្វើការនៅទីនោះ ដោយមួយផ្នែកស្ថិតក្រោមការចុះកិច្ចសន្យាផ្ទាល់ជាមួយនឹងអង្គការសមាគមអភិរក្សសត្វព្រៃ។ ដៃគូដទៃទៀតដែលសហការនៅក្នុងគម្រោងនេះមានដូចជាមជ្ឈមណ្ឌលសំរាសនា (Sam Veasna

Centre-SVC) គម្រោងជ្រលងដំរី (Elephant Valley Project-EVP) និង អង្គការក្តីសង្ឃឹមអន្តរជាតិ (World Hope International-WHI)។

ក្រុមអភិវឌ្ឍន៍ជនបទកម្ពុជា (CRDT) និង ដៃគូដទៃទៀតស្រដៀងគ្នានេះ នឹងទទួលខុសត្រូវក្នុងការអនុវត្តសកម្មភាពប្រកបរបរចិញ្ចឹមជីវិតជាក់លាក់ផ្សេងទៀត ឧទាហរណ៍ ការបង្កើតគម្រោងកសិកម្មប្រកបដោយនិរន្តរភាព ទេសចរណ៍ធម្មជាតិ និង គម្រោងលើកកម្ពស់មុខរបរក្រៅពីកសិកម្ម ជាដើម។ ការងារនេះពាក់ព័ន្ធជាចម្បងទៅនឹងសកម្មភាពនានាស្ថិតក្រោមអនុគោលដៅទី ៤ នៃ ផែនការការងារ ដោយក្នុងនោះក្រុមអភិវឌ្ឍន៍ជនបទកម្ពុជាក៏ចូលរួមក្នុងការផ្សព្វផ្សាយមួយចំនួនផងដែរ (អនុគោលដៅទី ៣ សកម្មភាពទី ៥)។

មជ្ឈមណ្ឌលសម្រាប់មនុស្ស និងព្រៃឈើ **(RECOFTC)** បានផ្តល់ការពង្រឹងសមត្ថភាពលើការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍មូលដ្ឋាន ដើម្បីលើកកម្ពស់ជីវភាពសហគមន៍ និងការអភិរក្សធនធានធម្មជាតិ និងជីវៈចម្រុះ។ ក្នុងនោះអង្គការ **RECOFTC** បានចងក្រងបង្កើតសហគមន៍ការពារធម្មជាតិស្រែព្រះ នៅក្នុងដែនជម្រកសត្វព្រៃកែវសីមា ដើម្បីអោយសហគមន៍មានសិទ្ធអំណាច និងមានសមត្ថភាព ក្នុងការគ្រប់គ្រងធនធានព្រៃឈើ និងជីវចម្រុះក្នុងសហគន៍អោយមាននិរន្តរភាព និងមានជីវភាពកាន់តែប្រសើរ។

## ២. ការតាមដាន និងអនុវត្តគម្រោង

ខាងក្រោមនេះគឺការបរិយាយសង្ខេបស្តីពីការអនុវត្តនូវគម្រោងរេដបូកតំបន់ដែនជម្រកសត្វព្រៃកែវសីមាចាប់ពីឆ្នាំ ២០១៨ ដល់ ២០១៩។ នៅក្នុងការរៀបចំគម្រោងនេះគោលបំណងចំនួន៤ត្រូវបានកំណត់ និងវាស់វែងតាមរយៈកិច្ចអន្តរាគមន៍ដោយផ្ទាល់ និងប្រយោល។ គោលបំណងទាំងនោះមាន៖
១. រក្សានូវភាពចម្រុះនៃប្រភេទព្រៃឈើទាំងអស់នៅក្នុងតំបន់
២. បង្កើននូវសុវត្ថិភាព និងផលិតភាពនៃធនធានធម្មជាតិ ដើម្បីគាំទ្រដល់ការចញ្ចឹមជីវិតរបស់សហគមន៍មូលដ្ឋាន
៣.មានដីស្រែចំការគ្រប់គ្រាន់សម្រាប់ទ្រទ្រង់ដល់ការចញ្ចឹមជីវិតរបស់សហគមន៍មូលដ្ឋាន ដែលរួមទាំងវប្បធម៌ប្រពៃណីផងដែរ
៤. បង្កើននូវចំនួនប្រភេទសត្វព្រៃ ដែលត្រូវការអភិរក្ស

សកម្មភាពជាក់លាក់ជាមួយគោលបំណងនិមួយៗនឹងត្រូវបានរៀបរាប់នៅក្នុងផ្នែកខាងក្រោម៖

### ២.១. កិច្ចអន្តរាគមន៍ដោយផ្ទាល់

**គោលបំណង #១៖ ឯកសារផែនការ និងឯកសារច្បាប់សម្រាប់តំបន់ដែនជម្រកសត្វព្រៃកែវសីមា និង ទីតាំងជុំវិញត្រូវបានអនុម័ត និង អនុវត្ត**

- សកម្មភាព #១៖ ប្រជាសហគមន៍ និងភាគីពាក់ព័ន្ធបានយល់ដឹងអំពីអនុក្រឹត្យដែនជម្រកសត្វព្រៃកែវសីមា និងច្បាប់តំបន់ការពារ
- សកម្មភាព # ២៖ ផែនការគ្រប់គ្រងត្រូវបានអនុម័ត និងអនុវត្ត(រួមមានការកំណត់តំបន់ និងបទបញ្ជា)
- សកម្មភាព #៣៖ អនុវត្តន៍យុទ្ធសាស្រ្តច្រករបៀងក្នុងខេត្តមណ្ឌលគីរី
- សកម្មភាព#៤៖ ការបង្កើតភាពជាដៃគូជាមួយផ្នែកឯកជន (ដើម្បីកាត់បន្ថយផលប៉ះពាល់បង្កឡើងដោយក្រុមហ៊ុន)
- សកម្មភាព # ៥ ៖ រៀបចំកិច្ចពិភាក្សាអំពី ការឆ្លងកាត់ព្រំដែនអន្តរជាតិ
- សកម្មភាព #៦៖ អនុវត្តការគ្រប់គ្រងដែល បត់បែនតាមស្ថានភាព

ក្រុមនៃសកម្មភាពនេះចូលរួមដោះស្រាយការគម្រាមកំហែងដោយផ្ទាល់ នូវភាពទន់ខ្សោយនៃច្បាប់ និងព្រំដែន មិនបានកំណត់ និងបទប្បញ្ញត្តិផ្សេងសម្រាប់តំបន់នេះ។

អនុក្រឹត្យលេខ ៨៣ ចុះថ្ងៃទី ០៩ ខែឧសភា ឆ្នាំ២០១៦ ត្រូវបានចែកចាយទៅឲ្យសហគមន៍មូលដ្ឋាននិងដៃគូរពាក់ព័ន្ធ។ បន្ថែមពីនេះទៀត ក្រុមការងាររបស់គម្រោងបានគាំទ្រ ការងាររបស់គម្រោងរេដបូកនៅតំបន់ដែនជម្រកសត្វព្រៃកែវសីមា តាមរយៈកិច្ចប្រជុំផ្សេងៗ សិក្ខាសាលាជាតិ និងកម្រិតតំបន់ ប្រព័ន្ធផ្សព្វផ្សាយ (ឧ. របាយការណ៍គម្រោង ព្រឹត្តិប័ត្រប្រចាំត្រីមាស និងករណីសិក្សា)។ ដំណើរទស្សនៈកិច្ចជាច្រើនបានរៀបចំឡើងនៅដែនជម្រកសត្វព្រៃកែវសីមាសម្រាប់ រដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល សហគមន៍ និងអ្នកផ្សេងៗទៀតក្នុងការលើកកម្ពស់ចំណេះដឹងដល់សាធារណជនទូទៅ។ ខិតបណ្ណ័រេដបូកនៃដែនជម្រកសត្វព្រៃកែវសីមា និងរបាយការណ៍ស្តីពីការអនុវត្តគម្រោងត្រូវបានចងក្រងឡើងនឹងបានចែកជូនទៅភាគីពាក់ព័ន្ធ។ សេចក្តីសង្ខេបនៃឯកសាររៀបចំគម្រោងជាភាសាខ្មែរប្រហែល ៤០០ ច្បាប់ត្រូវបានបោះពុម្ព និងចែកចាយទៅឲ្យភាគីពាក់ព័ន្ធ ។

មាត្រា ១១ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ឆ្នាំ២០០៨ ស្តីអំពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិនីមួយៗរួមមានតំបន់សហគមន៍ តំបន់ប្រើប្រាស់ដោយចីរភាព តំបន់អភិរក្ស និងតំបន់ស្នូល។ នៅថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៨ ក្រសួងបរិស្ថានបានចេញសេចក្តីសម្រេចលេខ០២៥សសរ.បស្ថ ស្តីពីការបង្កើតក្រុមការងារ រៀបចំកំណត់បែងចែកតំបន់គ្រប់គ្រាន់និងផែនការគ្រប់គ្រងដែនជម្រកសត្វព្រៃកែវសីមា ដែលមានសមាភាគចំនួន៣០នាក់ក្នុងនោះរួមមាន នាយកដ្ឋានពាក់ព័ន្ធនៃក្រសួងបរិស្ថាន មន្ទីរនិងរដ្ឋបាលថ្នាក់ក្រោមជាតិ នៃខេត្តមណ្ឌលគិរី និង ក្រចេះ នឹងអង្គការ WCS។ ក្រុមការងារនេះបានទទួលការបណ្តុះបណ្តាលការកសាងសមត្ថភាពដោយមន្ត្រីជំនាញមកពីក្រសួងបរិស្ថាន និង មានការគាំទ្រដោយអង្គការ WCS ដើម្បីធ្វើការផ្សព្វផ្សាយ និងពិគ្រោះយោបល់ជាមួយសហគមន៍ និងអ្នកពាក់ព័ន្ធ អំពីការកំណត់បែងចែងតំបន់គ្រប់គ្រង និងផែនការគ្រប់គ្រងដែនជម្រក ។ ជាលទ្ធផលសេចក្តីព្រៀងផែនទីការកំណត់បែងចែងតំបន់គ្រប់គ្រងត្រូវបានរៀបចំឡើង បន្ទាប់ពីការពិគ្រោះយោបល់នៅតាមសហគមន៍ ដែលរៀបចំឡើងនៅក្នុងភូមិចំនួន ៣២ និងមានអ្នកចូលរួមចំនួន ៧២២ នាក់ ដែល ២៧៩ ជាស្ត្រី ។ កិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ឃុំនៅក្នុងឃុំ ត្រូវបានរៀបចំឡើង ដើម្បីបង្ហាញនូវផែនទីព្រៀង និងប្រមូលធាតុចូលបន្ថែមពីអ្នកពាក់ព័ន្ធកាលពីខែ មិថុនា ឆ្នាំ ២០១៩ ដោយមានការចូលរួម ២២២ នាក់ ដែល ២៤នាក់ជាស្ត្រី។ កិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ខេត្ត ត្រូវបានរៀបចំឡើង ដើម្បី ប្រមូលធាតុចូលបន្ថែមពីអ្នកពាក់ព័ន្ធកាលពីខែ តុលា ឆ្នាំ ២០១៩ ដោយមានការចូលរួម ១១៤ នាក់ ដែល ១៣នាក់ជាស្ត្រី។



រូបទី 3 កិច្ចប្រជុំផ្សព្វផ្សាយ និង ពិគ្រោះយោបល់ជាមួយសហគមន៍អំពីការបែងចែកតំបន់គ្រប់គ្រង



រូបទី 4 សេចក្ដីព្រៀងផែនទី ការបែងចែងតំបន់គ្រប់គ្រងដែនជម្រកសត្វព្រៃកែវសីមា

មន្ត្រីគម្រោង និងដែនជម្រកសត្វព្រៃកែវសីមាបានចូលរួមក្នុងការផ្តល់នូវធាតុចូល និងទិន្នន័យពាក់ព័ន្ធនឹងដំណើរការរៀបចំផែនការដីធ្លី (Spatial Planning) ក្នុងខេត្តមណ្ឌលគិរី តាមរយៈកិច្ចប្រជុំដែលរៀបចំឡើងដោយអង្គការ WWF សហការជាមួយក្រសួងបរិស្ថាន និងរដ្ឋបាលខេត្តមណ្ឌលគិរី។

ក្រុមការងារគម្រោងបានចូលរួមកិច្ចប្រជុំអន្តរក្រសួង និងវិស័យឯកជនជាច្រើនលើក ទាក់ទងនឹងគម្រោងសិក្សាអំពីរ៉ែលោហៈរបស់ក្រុមហ៊ុន Rennaisance[12] នៅក្នុងដែនជម្រកសត្វព្រៃកែវសីមា ដែលអាចធ្វើអោយមានផលប៉ះពាល់ដល់កិច្ចព្រមព្រៀងជាលក្ខណៈអន្តរជាតិក្នុងការលក់ឥណទានកាបូន ដែលត្រូវបានចុះហត្ថលេខារវាងរាជរដ្ឋាភិបាលកម្ពុជា និងអ្នកទិញឥណទានកាបូន ជាពិសេស ផលប៉ះពាល់ទៅលើព្រៃឈើ ជីវៈចម្រុះ និងសហគមនជនជាតិដើមភាគតិចដែលកំពុងរស់នៅក្នុងដែនជម្រកសត្វព្រៃកែវសីមាថែមទៀតផង។ គម្រោងក៏បានផ្តល់អនុសាសន៍ និងវិធានការ ដើម្បីកាត់បន្ថយផលប៉ះពាល់ដែលអាច បង្កឡើងដោយគម្រោងសិក្សាអំពីរ៉ែលោហៈរបស់ក្រុមហ៊ុននៅក្នុងដែនជម្រកសត្វព្រៃកែវសីមា។

កិច្ចប្រជុំត្រួតពិនិត្យទៅលើការអនុវត្តប្រចាំឆមាស និងប្រចាំឆ្នាំត្រូវបានរៀបចំឡើងជាប្រចាំ ដើម្បីកែសម្រួលសកម្មភាព និងរៀបចំផែនការបន្ទាប់ ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធ ដូចជា សហគមន៍ អាជ្ញាធរមូលដ្ឋាន មន្ទីបរិស្ថាន អង្គការដៃគូរ និង ក្រសួងបរិស្ថាន។

| គោលបំណងទី ១ | សកម្មភាពសំខាន់ៗ | ស្ថានភាព |
|---|---|---|
| សកម្មភាព #១៖ អនុក្រឹត្យត្រូវបានផ្សព្វផ្សាយក្នុងចំណោមមន្ត្រីរដ្ឋាភិបាល សហគមន៍ អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន និង សាធារណជនទូទៅ | • អនុក្រឹត្យដែនជម្រកសត្វព្រៃកែវសីមាឆ្នាំ ២០១៦<br>• អនុក្រឹត្យជាភាសាខ្មែរបានចែកចាយទៅឲ្យតំណាងសហគមន៍មូលដ្ឋាន និងដៃគូរ | បញ្ចប់ |
| | • គាំទ្រការងារគម្រោងរេដបូកនៅតំបន់ដែនជម្រកសត្វព្រៃកែវសីមា តាមរយៈ កិច្ចប្រជុំផ្សេងៗ សិក្ខាសាលា ប្រព័ន្ធផ្សព្វផ្សាយ<br>• ផ្សព្វផ្សាយ និង ខិត្តបណ្ណ័និង ឯកសារគម្រោងនិងអំពីគម្រោងរេដបូកនៅដែនជម្រកសត្វព្រៃកែវសីមា | កំពុងអនុវត្ត |
| សកម្មភាព # ២៖ ផែនការគ្រប់គ្រង និងការបែងចែកតំបន់គ្រប់គ្រប់គ្រងត្រូវបាន អនុម័តនិងអនុវត្ត | • ក្រុមការងាររៀបចំកំណត់បែងចែកតំបន់គ្រប់គ្រងនៅដែនជម្រកសត្វព្រៃកែវសីមា<br>• សេចក្តីព្រៀងផែនទីការកំណត់បែងចែងតំបន់គ្រប់គ្រង | កំពុងអនុវត្ត |
| | • សេចក្តីព្រៀងផែនការគ្រប់គ្រងដែនជម្រកសត្វព្រៃកែវសីមា | កំពុងអនុវត្ត |
| សកម្មភាព #៣៖ គាំទ្រដល់ដំណើរការរៀបចំផែនការដីធ្លី(Spatial Planning) ក្នុងខេត្តមណ្ឌលគិរី | • ការផ្តល់នូវធាតុចូល និងទិន្នន័យពាក់ព័ន្ធដែនជម្រកសត្វព្រៃកែវសីមាសម្រាប់ដំណើរការរៀបចំផែនការដីធ្លី (Spatial Planning) ក្នុងខេត្តមណ្ឌលគិរី | កំពុងអនុវត្ត |
| សកម្មភាព #៤៖ ការបង្កើតភាពជាដៃគូជា | • ចូលរួមកិច្ចប្រជុំអន្តរក្រសួង វិសយ័ឯកជន ជាច្រើនលើក | កំពុងអនុវត្ត |

[12] http://www.renaissanceminerals.com.au/

| គោលបំណងទី ១ | សកម្មភាពសំខាន់ៗ | ស្ថានភាព |
|---|---|---|
| មួយផ្នែកឯកជនដើម្បីកាត់បន្ថយផលប៉ះពាល់ | ទាក់ទងនឹងគម្រោងសិក្សាអំពីរ៉ែលោហៈរបស់ក្រុមហ៊ុន Rennaisance<br>• ផ្តល់អនុសាសន៍ និងវិធានការដើម្បីកាត់បន្ថយផលប៉ះពាល់ | |
| សកម្មភាព #៥៖ រៀបចំកិច្ចពិភាក្សាអំពីការឆ្លងកាត់ព្រំដែនអន្តរជាតិ | • កិច្ចប្រជុំជាប្រចាំជាមួយគូភាគីវៀតណាមក្នុងដើម្បី ពិភាក្សា កិច្ចសហប្រតិបត្តការ តាមព្រំដែន លើបញ្ហាបទល្មើសព្រៃឈើនិងការជួញដូរសត្វព្រៃ | កំពុងអនុវត្ត |
| សកម្មភាព #៦៖អនុវត្តការគ្រប់គ្រងដែលបត់បែនតាមស្ថានភាព | • កិច្ចប្រជុំជាប្រចាំក្នុងការកែសម្រួលសកម្មភាព និងផែនការ<br>• សិក្ខាសាលាផែនការប្រចាំឆ្នាំ (២០១៨ និង ២០១៩) | កំពុងអនុវត្ត |

**គោលបំណង #២៖កាត់បន្ថយបទល្មើសសត្វព្រៃ និង ព្រៃឈើតាមរយៈការអនុវត្តច្បាប់ដោយផ្ទាល់**

- សកម្មភាព #១៖ ជំរុញការអនុវត្តច្បាប់ និង អនុក្រឹត្យស្តីពី សត្វព្រៃ ព្រៃឈើ និងតំបន់ការពារ តាមរយៈការល្បាត
- សកម្មភាព #២៖ បង្កើត និង អនុវត្តក្របខ័ណ្ឌ តាមដានការអនុវត្តច្បាប់
- សកម្មភាព #៣៖ ធានាឱ្យមានស្នាក់ការល្បាត បរិក្ខារ និង បុគ្គលិកគ្រប់គ្រាន់
- សកម្មភាព # ៤៖ ធានាសមត្ថភាព គ្រប់គ្រាន់សម្រាប់បុគ្គលិកល្បាត
- សកម្មភាព #៥៖ទំនាក់ទំនងជាមួយ អាជ្ញាធរខេត្ត អាជ្ញាធរជាតិ និងអាជ្ញាធរដទៃទៀត
- សកម្មភាព #៦៖ បង្កើតប្រព័ន្ធតាមដាន និង/ឬ ល្បាតនៅតាមសហគមន៍

សកម្មភាពទាំងនេះ ផ្តោតជាសំខាន់ទៅលើការគាំទ្រការពង្រឹងការអនុវត្តច្បាប់ដែលដឹកនាំដោយមន្ត្រីរដ្ឋាភិបាល ក្នុងការល្បាតដោយផ្ទាល់ ដើម្បីទប់ស្កាត់បទល្មើសធនធានធម្មជាតិនៅក្នុងដែនជម្រក។ សកម្មភាពល្បាត និងលទ្ធផល ត្រូវបានគ្រប់គ្រងដោយប្រើប្រាស់ ឧបករណ៍សម្រាប់ធ្វើការត្រួតពិនិត្យនិងរាយការណ៍ព័ត៌មានអំពីទីតាំងភូមិសាស្ត្រ (SMART) ដែលផ្តល់ទាំងទិន្នន័យកំពុងដំណើរការ នៃការកត់ត្រានូវសកម្មភាពបទ ល្មើស នៅក្នុងតំបន់ និងសម្រាប់រៀបចំគោលដៅល្បាត។ តំបន់ដែនជម្រកសត្វព្រៃកែវសីមា បានរក្សានូវសកម្មភាពល្បាតជាទៀងទាត់ចាប់តាំងពីការចាប់ផ្តើមនៃគម្រោងរេដបូក។ សកម្មភាពទាំងអស់បានសង្ខេបនូវក្នុងតារាងខាងក្រោម បានចូលរួមដោះស្រាយការគំរាមកំហែងដោយផ្ទាល់ ដែលបណ្តាលមកពីការកាប់ឆ្ការព្រៃឈើ/ទន្ទ្រានដីព្រៃដោយបុគ្គល ការបរបាញ់សត្វព្រៃ កាប់ឈើខុសច្បាប់ និងការដកហូតអនុផលព្រៃឈើលើសការកំណត់។ សកម្មភាពសំខាន់ៗនៅក្នុងគោលបំណង២៖ “កាត់បន្ថយបទល្មើសសត្វព្រៃ និង ព្រៃឈើពង្រឹងលើការអនុវត្តច្បាប់ដោយផ្ទាល់”

| គោលបំណងទី២ | សកម្មភាពសំខាន់ៗ | ស្ថានភាព |
|---|---|---|
| សកម្មភាព #១៖ ជំរុញការអនុវត្តច្បាប់ និង អនុក្រឹត្យស្តីពីតំបន់ការពារ និង សត្វព្រៃ តាមរយៈការយាមល្បាត | • ការល្បាតដោយថ្មើរជើង ម៉ូតូ និងរថយន្តរបស់ក្រុមពង្រឹងការអនុវត្តច្បាប់ដោយសហការជាមួយកងកំលាំងប្រដាប់អាវុធ<br>• ក្រុមល្បាតចម្រុះបានធ្វើការល្បាតចំនួន ៥០០៥ និងក្រុមល្បាតសហគមន៍ ៥៦ | កំពុងបន្ត |

| គោលបំណងទី២ | សកម្មភាពសំខាន់ៗ | ស្ថានភាព |
|---|---|---|
| | • ឃាត់ខ្លួន /បញ្ជូនទៅតុលាការចំនួន ៧៥ នាក់ កិច្ចសន្យាអប់រំលាយលក្ខអក្សចំនួន ២៥៧ | |
| សកម្មភាព #២៖ បង្កើត និងអនុវត្តក្របខ័ណ្ឌតាមដានការអនុវត្តច្បាប់ | • ឧបករណ៍សម្រាប់ធ្វើការត្រួតពិនិត្យនិងរាយការណ៍ព័ត៍មានអំពីទីតាំងភូមិសាស្ត្រ (SMART) នៅកន្លែង និងប្រើសម្រាប់តាមដានសកម្មភាពល្បាត | កំពុងបន្ត |
| សកម្មភាព #៣ ៖ ធានាឱ្យមានប៉ុស្តិ៍ល្បាត បរិក្ខារ និងបុគ្គលិកគ្រប់គ្រាន់ | • ធ្វើបច្ចុប្បន្នភាពឧបករណ៍ល្បាត ថែរក្សាអនុប៉ុស្តិ៍ល្បាត និងសង់បន្ថែមប៉ុស្តិ៍ល្បាត (ចំនុចភ្នំសេរ៉ា) | កំពុងបន្ត |
| | • បង្កើនចំនួនបុគ្គលិកល្បាត និងការចូលរួមរបស់សហគមន៍ជាពិសេសនៅក្នុងសហគមន៍តំបន់ការពារធម្មជាតិ (ស្រែព្រះ) | កំពុងបន្ត |
| សកម្មភាព #៤ ៖ ធានាសមត្ថភាព គ្រប់គ្រាន់សម្រាប់បុគ្គលិកល្បាត | • ផ្តល់វគ្គបណ្តុះបណ្តាលចំនួន ៧ ដល់ក្រុមអនុវត្តច្បាប់ និងក្រុមល្បាតសហគមន៍ដែលមានអ្នកចូលរួមសរុបចំនួន ២២៣ នាក់ (ស្រីចំនួន ១០)<br>• ការបណ្តុះបណ្តាលអំពីការប្រើប្រាស់ Drone សម្រាប់ជួយដល់ការងារល្បាត | កំពុងបន្ត |
| សកម្មភាព #៥៖ ទំនាក់ទំនងជាមួយ អាជ្ញាធរខេត្ត អាជ្ញាធរជាតិ និងអាជ្ញាធរដទៃទៀត | • បន្តជួបទំនាក់ទំនងជានិច្ចជាកាល ជាមួយអាជ្ញាធរ មូលដ្ឋាន ថ្នាក់ខេត្ត ថ្នាក់ជាតិ ក្នុងការជំរុញការអនុវត្តច្បាប់ និងដោះស្រាយបញ្ហាដែលកើតមានឡើងនៅក្នុងដែនជម្រក | កំពុងបន្ត |
| សកម្មភាព #៦៖ បង្កើតប្រព័ន្ធ តាមដាន និង ឬ ល្បាត/ នៅតាមសហគមន៍ | • កំណត់សហគមន៍ចូលរួម និងជ្រើសរើសសមាជិកក្រុមល្បាតនៅក្នុងសហគមន៍តំបន់ការពារធម្មជាតិស្រែព្រះ<br>• បង្កើតក្រុមល្បាតសហគមន៍នៅតាមសហគន៍ក្នុងដែន<br>• ផ្តល់ឧបករណ៍ សំភារៈ និងការបណ្តុះបណ្តាលដល់ក្រុមល្បាតសហគមន៍ | កំពុងបន្ត |




រូបទី 5 ផែនទីបង្ហាញពីការវិភាគលើភាពញឹកញាប់នៃគន្លងល្បាត ២០១៩ (ក្រុមអនុវត្តច្បាប់)




**រូបទី 6** ផែនទីបង្ហាញពីការវិភាគលើភាពញឹកញាប់នៃគន្លងល្បាត (ល្បាតសហគមន៍) ឆ្នាំ២០១៨




រូបទី 7 វគ្គបណ្តុះបណ្តាលពីការប្រមូលទិន្នន័យល្បាត SMART



រូបទី 8 វគ្គបណ្តុះបណ្តាលពីការប្រើប្រាស់ Drone

ក្រុមល្បាតសហគមន៍គឺកំពុងដំណើរការល្បាត និងបន្តបង្កើតនៅតាមភូមិគោលដៅ។ សហគមន៍ត្រូវបានជួយទាំងធនធាន និងបង្ហាត់បង្រៀនក្នុងការចុះល្បាត។ ក្រុមល្បាតនូវសហគមន៍ទាំងនេះបានបង្កើតឡើង ដើម្បីបន្ថែមលើសកម្មភាពអនុវត្តច្បាប់ជាប្រចាំ។ សហគមន៍ល្បាតប្រើប្រាស់ប្រព័ន្ធ SMART ដូចក្រុមអនុវត្តច្បាប់របស់រដ្ឋាភិបាលដែរក្នុងការត្រួតពិនិត្យសកម្មភាពល្បាត។ វគ្គបណ្តុះបណ្តាល និងទស្សនៈកិច្ចសិក្សាត្រូវបានផ្តល់ទៅឲ្យក្រុមអនុវត្តច្បាប់ និងក្រុមល្បាតសហគមន៍ នូវតែបន្ត ជាបន្តបន្ទាប់។ ក្រុមសហគមន៍ធ្វើការដោយផ្ទាល់ជាមួយអង្គធរមូលដ្ឋាន ក្នុងការបង្រ្កាបបទល្មើសព្រៃឈើ ។ ខណៈពេលដែល ការប្រតិបត្តគម្រោងបានទទួលលើសពីការព្យាករពីមុន សម្ពាធពីការរំលោភបំពានយកដីធ្លីដោយខុសច្បាប់និងការប្រមាញ់ ក៏កើនឡើងដែរ ដូច្នេះវានឹងតម្រូវឱ្យមានការកើនឡើងនៅចំនួនបុគ្គលិកដើរល្បាត (ទាំងបុគ្គលិករដ្ឋាភិបាល និងសហគមន៍) ដើម្បីដោះស្រាយនូវការកើនឡើងការគំរាមកំហែងនេះ។ ក្រុមល្បាតសហគមន៍ត្រូវបានផ្អាកសកម្មភាពមួយរយៈក្នុងឆ្នាំ២០១៩ ដើម្បីពិភាក្សាអំពីសុវត្ថិភាព និងច្រងក្រងនូវនិតិវិធីល្បាត



រូបទី 9 ក្រុមល្បាតសហគមន៍តំបន់ការពារស្រែព្រះ

ដើម្បីធានាបាននូវ សុវត្ថិភាពរបស់សហគមន៍ដែលចូលរួមល្បាត។ ក្រុមល្បាតសហគមន៍ត្រូវបានត្រួតពិនិត្យឡើងវិញ និងចងក្រងនៅតាមភូមិអាទិភាពមួយចំនួន ដូចជាសហគមន៍ល្បាតនៃសហគមន៍តំបន់ស្រែព្រះ។ សហគមន៍បានចុះល្បាតដោយមានការសហការជាមួយមន្ត្រីឧទ្យានុរក្ស។

តារាងទី 1 លទ្ធផលនៃការល្បាតរបស់ក្រុមអនុវត្តច្បាប់ និងសហគមន៍សម្រាប់ឆ្នាំ ២០១៨ និង២០១៩

| **ពត៍មានល្បាត** | **ក្រុមល្បាតសហគមន៍** | | **ក្រុមពង្រឹងការអនុវត្តច្បាប់** | | **សរុប** |
|---|---|---|---|---|---|
| | **២០១៨** | **២០១៩** | **២០១៨** | **២០១៩** | |
| ចំនួនល្បាត | ៥៦ | ០ | ២.៣០៥ | ២៧០០ | ៥.០៦១ |
| ចំនួនថ្ងៃ | ១៤៦ | ០ | ២.៥៤៣ | ៣០៩២ | ៣.២៣៨ |
| ចំនួនយប់ | ៩០ | ០ | ២៣៨ | ៣៩២ | ៥.៧៨១ |
| ចម្ងាយ (គម) | ៥.០៥០ | ០ | ៩៥.៣២៨ | ១២៨.៧៨៥ | ២២៩.១៦៣ |

| **ការបរិយាយ** | **២០១៨** | **២០១៩** | **២០១៨** | **២០១៩** | **សរុប** |
|---|---|---|---|---|---|
| មនុស្សត្រូវបានឃាត់ខ្លួន | ១០ | ០ | ២៦ | ៣៩ | ៧៥ |
| លិខិតព្រមានដែលបានចេញ | ៣០ | ០ | ១០០ | ១២៧ | ២៥៧ |
| អន្ទាក់ត្រូវបានរឹបអូសយក | ២១ | ០ | ៣២១ | ១៧៥ | ៥១៧ |
| កាំភ្លើងបានធ្វើទុកជាមោឃៈ | 0 | ០ | ៤ | ២ | ៦ |

| | | | | | |
|---|---|---|---|---|---|
| កាំភ្លើងខ្យល់ត្រូវបានរឹបអូស | ៤ | ០ | ២១ | ៦ | ៣១ |
| ផ្ទះ រឺ ស្នា | ០ | ០ | ០ | ២ | ២ |
| រណារយន្តរឹបអូសបាន | ៨៤ | ០ | ២៨០ | ២១១ | ៥៧៥ |
| ពូថៅត្រូវបានរឹបអូស | ៤ | ០ | ៣ | ៣ | ១០ |
| រណាដៃបានរឹបអូស | ០ | ០ | 0 | 0 | ០ |
| កាំបិតផ្គាក់ត្រូវបានរឹបអូស | ៦៣ | ០ | ៩៧ | ៥១ | ២១១ |
| ម៉ូតូត្រូវបានរឹបអូស | ១៥ | ០ | ៩៥ | ១៣២ | ២៤២ |
| រថយន្តរឹបអូស | ០ | ០ | ៣១ | ៤៧ | ៧៨ |
| រថយន្តដឹកត្រូវបានរឹបអូស | ០ | ០ | ០ | ០ | ០ |
| គោយន្តបានរឹបអូស | ០ | ០ | ០ | ២ | ២ |

**គោលបំណងទី៣៖ ការប្រើប្រាស់ដី និងធនធានធម្មជាតិ នៅក្នុងតំបន់ស្នូលសហគមន៍គឺមាននិរន្តរភាព**

- សកម្មភាពទី១៖ គាំទ្រសហគមន៍ដើម្បីការពារដីរបស់ពួកគេនិងរៀបចំផែនការប្រើប្រាស់ដីធ្លី
- សកម្មភាពទី២៖ ពង្រឹងការចុះបញ្ជីសហគមន៍ជនជាតិដើមភាគតិច
- សកម្មភាពទី៣៖ ការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច
- សកម្មភាពទី៤៖ ការកំណត់ព្រំប្រទល់ដែនជម្រកសត្វព្រៃកែវសីមា
- សកម្មភាពទី៥៖ សកម្មភាពផ្សព្វផ្សាយ និងការប្រាស្រ័យទំនាក់ទំនង គឺត្រូវបានអនុវត្តន៍នៅក្នុងសហគមន៍គោលដៅ
- សកម្មភាពទី៦៖ ទំនាក់ទំនងជាមួយក្រុមប្រឹក្សាឃុំ និងភ្នាក់ងារដ៏ទៃទៀត
- សកម្មភាពទី៧៖ ផ្សារភ្ជាប់ទំនាក់ទំនងជាមួយអង្គការសង្គមស៊ីវិលដែលកំពុងដំណើរការនៅក្នុងតំបន់គម្រោង
- សកម្មភាពទី៨៖ ពង្រឹងនូវសមត្ថភាពរបស់បុគ្គលិកគម្រោងអោយមានលក្ខណៈគ្រប់គ្រាន់



រូបទី 10 កិច្ចប្រជុំស្ដីពីការរៀបចំបទបញ្ញាផ្ទៃក្នុងសហគមន៍ចុះបញ្ជីដីធ្លីជនជាតិដើមភាគតិចភូមិពូកេះ

គម្រោងនៅតែបន្តគាំទ្រដល់ដំណើរការចុះបញ្ជីដីធ្លីជនជាតិដើមភាគតិច និងការធ្វើផែនការប្រើប្រាស់ដីនៅក្នុងសហគមន៍ ដែលភូមិចំនួន៦ ក្នុងចំណោមភូមិចំនួន ១៤ដែលចាប់អារម្មណ៍ ក្នុងការចុះបញ្ជីសម្ហហភាពសហគមន៍ជនជាតិដើមភាគតិច

បានទទួលបានប័ណ្ណកម្មសិទ្ធិជាផ្លូវការ។ សហគមន៍ចំនួន៨ភូមិទៀត កំពុងដំណើការនីតិវិធីនៃការចុះបញ្ជីដីសហគមន៍ ដែលក្នុងនោះ សហគមន៍ចំនួន៥ភូមិកំពុងស្ថិតនៅក្រសួងបរិស្ថានក្នុងការត្រួតពិនិត្យ ដើម្បីផ្តល់ប្លង់កម្មសិទ្ធសហមូហភាព។ ក្រុមការងារក៏បានសហការជាមួយមន្ត្រីសុរិយោដីខេត្ត ក្រុមប្រឹក្សាឃុំ មេភូមិ គណៈកម្មាធិការ និងសមាជិកសហគមន៍ ចុះកំណត់ វាស់វែង និងធ្វើផែនទីដីប្រើប្រាស់សហគមន៍ចុះបញ្ជីដីជនជាតិដើមភាគតិចនៅភូមិពូកេះដែលមានអ្នកចូលរួមចំនួន ៤០នាក់ ដែលមានអ្នកចូលរួមជាស្ត្រីចំនួន ៦នាក់ កាលពីថ្ងៃទី១៨-២០ ខែវិច្ឆិកា ឆ្នាំ២០១៨។ កាលពីខែសីហាឆ្នាំ២០១៩ ក៏មានការប្រជុំដើម្បីពិភាក្សាអំពីតួនាទីភារកិច្ចរបស់គណកម្មការសហគមន៍ និងពង្រឹងការគ្រប់គ្រងដីសមូសហភាពសហគមន៍នៅភូមិ ស្រែអណ្តោល និង ពូគង់។ ដើម្បីពង្រឹងភូមិដែលបានចុះបញ្ជីដីធ្លីជនជាតិដើមភាគតិចមានស្រាប់ ដូចជាភូមិអូរប្រាភូមិអណ្តូងក្រឡឹង ភូមិកាទី ពូត្រាំ មានកិច្ចប្រជុំជាទៀងទាត់ជាមួយសហគន៍មូលដ្ឋាន និងភាគីពាក់ព័ន្ធត្រូវបានធ្វើឡើងផងដែរ ក្នុងការពង្រឹងការប្រើប្រាស់ដីរបស់ពូកគេ។

កិច្ចប្រជុំពិគ្រោះយោបល់ ស្តីពីការបោះបង្គោលព្រំប្រទល់តំបន់ការពារធម្មជាតិដែនជម្រកសត្វព្រៃកែវសីមា នៅថ្ងៃទី ៣០ ខែតុលា ឆ្នាំ២០១៩ ដែលបានរៀបចំដោយមានកិច្ចសហការជាមួយនាយកដ្ឋានអភិរក្សតំបន់ការពារធម្មជាតិដីគោកខាងកើតទន្លេមេគង្គ នៃអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិក្រសួងបរិស្ថាន។

<table>
<tr><th>គោលបំណងទី៣</th><th>សកម្មភាពសំខាន់ៗ</th><th>ស្ថានភាព</th></tr>
<tr><td>សកម្មភាពទី១៖ គាំទ្រសហគមន៍ដើម្បីការពារដីរបស់ពួកគេនិងរៀបចំផែនការប្រើប្រាស់ដីធ្លី</td><td>• បន្តពង្រឹងការគ្រប់គ្រងដីធ្លី និងដោះស្រាយបញ្ហានៅតាមសហគមន៍<br>• ផែនការប្រើប្រាស់ដីធ្លីដោយមានការចូលរួមត្រូវបានបង្កើតឡើងនៅក្នុងសហគមន៍<br>• ពង្រឹងសម្ថតិភាពគណកម្មការគ្រប់គ្រងសហគមន៍</td><td>កំពុងបន្ត</td></tr>
<tr><td>សកម្មភាពទី២៖ពង្រឹងការចុះបញ្ជីសហគមន៍ជនជាតិដើមភាគតិច</td><td rowspan="2">• សហគមន៍ជនជាតិដើមភាគតិចចំនួន ៦ ទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លីសមូហភាពជនជាតិដើមភាគតិចនៅក្នុងគម្រោង<br>• សហគមន៍ជនជាតិដើមភាគតិចចំនួន ៨ កំពុងឋិតនៅក្នុងដំណើរការចុះបញ្ជី<br>• តំបន់សហគមន៍ ដែលបានចុះបញ្ជីរួច និងឋិតនៅក្នុងដំណើរការនឹងត្រូវដាក់បញ្ចូលជាតំបន់សហគមន៍នៅក្នុងដំណើរការកំណត់បែងចែកតំបន់ដែនជម្រកសត្វព្រៃកែវសីមា</td><td>កំពុងបន្ត</td></tr>
<tr><td>សកម្មភាពទី៣៖ការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច</td><td></td></tr>
<tr><td>សកម្មភាពទី៤៖ការកំណត់ព្រំប្រទល់ដែនជម្រកសត្វព្រៃកែវសីមា</td><td>• ការបោះបង្គោលព្រំប្រទល់ដែនជម្រកសត្វព្រៃកែវសីមា ត្រូវបានធ្វើឡើងដោយក្រុមការងារក្រសួងបរិស្ថាន និងមន្ទីបរិស្ថាន</td><td>កំពុងបន្ត</td></tr>
<tr><td>សកម្មភាពទី៥៖សកម្មភាពផ្សព្វផ្សាយ និងការប្រាស្រ័យទំនាក់ទំនងគឺត្រូវបាន អនុវត្តន៍នៅក្នុងសហគមន៍គោលដៅ</td><td>• ប្រជុំជាទៀងទាត់ជាមួយសហគមន៍ និងអ្នកពាក់ព័ន្ធ ដើម្បីពង្រឹងនូវសហគមន៍ដែលបានចុះបញ្ជីដីធ្លីជនជាតិដើមភាគតិចនិងដោះស្រាយនូវបញ្ហាផ្សេងៗនៅក្នុងដែនជម្រកសត្វព្រៃកែវសីមា</td><td>កំពុងបន្ត</td></tr>
<tr><td>សកម្មភាពទី៦៖ទំនាក់ទំនងជាមួយក្រុមប្រឹក្សាឃុំ និងភ្នាក់ងារដ៏ទៃទៀត</td><td>• សហការជាមួយក្រុមប្រឹក្សាឃុំ ប្រធានភូមិ និងមន្ទីពាក់ព័ន្ធក្នុងដំណើរការចុះបញ្ជីដីធ្លីជនជា</td><td>កំពុងបន្ត</td></tr>
</table>

| | | |
|---|---|---|
| | តិដើមភាគតិច និងការរៀបចំសហគមន៍តំបន់ការពារ<br>• ដាក់បញ្ចូលសកម្មភាពគម្រោងទៅក្នុងផែនការវិនិយោគឃុំ/សង្កាត់ | |
| សកម្មភាពទី៧៖ផ្សារភ្ជាប់ទំនាក់ទំនងជាមួយអង្គការសង្គមស៊ីវិល ដែលកំពុងដំណើរការនៅក្នុងតំបន់គម្រោង | • ធ្វើការយ៉ាងជិតស្និតជាមួយអង្គការមិនរដ្ឋាភិបាលមូលដ្ឋានដែលជាដៃគូ ដូចជា ក្រុមអភិវឌ្ឍន៍ជនបទកម្ពុជា (Cambodia Rural Development Team-CRDT) អង្គការក្តីសង្ឃឹមអន្តរជាតិ (World Hope International-WHI) មជ្ឈមណ្ឌលសំវាសនា (Sam Veasna Centre-SVC) និង គម្រោងជ្រលងដំរី (Elephant Valley Project-EVP) | កំពុងបន្ត |
| សកម្មភាពទី៨៖ពង្រឹងនូវសមត្ថភាពរបស់បុគ្គលិកគម្រោងដែលមានលក្ខណ:គ្រប់គ្រាន់ | • វគ្គបណ្តុះបណ្តាលត្រូវបានផ្តល់អោយបុគ្គលិក ដូចជានិតិវិធីនៃការចុះបញ្ជីដីធ្លីជនជាតិដើមភាគតិច ការធ្វើផែនទីបឋម ផែនការប្រើប្រាស់ដីដោយមានការចូលរួម ការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ ការកំណត់ការបែងចែកតំបន់គ្រប់គ្រង ការប្រែប្រួលអាកាសធាតុ រេដបូក យេនឌ័រ និងប្រព័ន្ធធានាសុវត្ថិភាព | កំពុងបន្ត |

**សកម្មភាពសំខាន់ៗនៅក្នុងគោលបំណងទី៤៖ ជួយគាំទ្រជីវភាពរស់នៅ និងការយល់ដឹងពីការអភិរក្ស**

គម្រោងបានសម្របសម្រួលចងក្រងសហគមន៍តំបន់ការពារធម្មជាតិ ដែលជាយុទ្ធសាស្ត្រនៃការគ្រប់គ្រងព្រៃឈើដោយសហគមន៍ប្រកបដោយនិរន្តរភាព និង លើកកំពស់ជីវភាពសហគមន៍។ សហគមន៍ តំបន់ការពារធម្មជាតិស្រែព្រះនៃដែនជម្រកសត្វព្រៃកែវសីមា មានទីតាំងស្ថិតក្នុងភូមិសាស្ត្រភូមិពូគង់ ភូមិពូចារ ភូមិអូរប្រា ឃុំស្រែព្រះ ស្រុកកែវសីមា ខេត្តមណ្ឌលគិរី ទទួលបានប្រកាសទទួលស្គាល់ការបង្កើតសហគមន៍ ពីក្រសួងបរិស្ថាននៅថ្ងៃទី២១ ខែមករា ឆ្នាំ២០១៩ និងបានចុះកិច្ចព្រមព្រៀងជាមួយអគ្គនាយកដ្ឋានជីវភាពសហគមន៍ នៃក្រសួងបរិស្ថាន នៅថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ២០១៩។ ក្រុមអាជីវកម្មខ្នាតតូចឬស្សីនៃសហគមន៍តំបន់ការពារធម្មជាតិស្រែព្រះ បានបង្កើតឡើងនៅខែវិច្ឆិកា ឆ្នាំ២០១៨ និងបានដំណើរការអាជីវកម្មរបស់ខ្លួននៅខែមីនា ឆ្នាំ២០១៩ ក្នុងគោលបំណងជួយសហគមន៍បង្កើតនូវប្រាក់ចំណូលបន្ថែមដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ពួកគាត់ និងដើម្បីស្តារព្រៃឫស្សីឡើងវិញ។



រូបទី 11 កិច្ចប្រជុំរវាងក្រុមសហគ្រាសសហគមន៍ប្រមូលឬស្សី ជាមួយនិងវិស័យឯកជន

ក្រុមការងារអង្គការសមាគមន៍អភិរក្សសត្វព្រៃកម្ពុជាកំពង់ចាប់ផ្ដើមសកម្មភាពអង្ករអោយបិស(IBIS) ដែលធ្វើការយ៉ាងជិតស្និទជាមួយប្រជាកសិករ ដើម្បីផលិតចេញបាននូវអង្ករ និងផលិតផលកសិកម្ម ដែលមានទំនួលខុសត្រូវលើសង្គម ការការពារជីវៈចម្រុះ។

ចំណូលដែលទទួលបានពីការលក់ឥណទានកាបូន របស់គម្រោងរេដបូកដែនជម្រកសត្វព្រៃកែវ ប្រមាណជិត៥០ភាគរយ បានផ្ដល់ដល់សហគមន៍ដែលចូលរួមទាំង២០ភូមិ ក្នុងការអភិវឌ្ឍន៍សហគមន៍ ក្នុងការលើកកំពស់នូវជីវភាពរបស់សហគមន៍។ នៅក្នុងជំហ៊ានដំបូង សហគមន៍ទទួលបាននូវគម្រោង ជាអាទិភាពដូចជា រោងប្រជុំសហគមន៍ អណ្ដូងស្នប់ បណ្ដាញទឹកស្អាត ជួសជុលស្ពាន កែលំអរផ្លូវក្នុងភូមិ កែលំអរទីធ្លាសាលារៀន បង្គន់អនាម័យ (តារាងទី២)។ល។ សហគមន៍ភូមិពូត្រាំបានឯកភាពយកថវិការទៅបោះបង្គោលព្រំដីសហគមន៍ជនជាតិដើមភាគតិចដែលបានទទួលស្គាល់ព្រំប្រទល់តាំងពីឆ្នាំ ២០១៥។ កិច្ចប្រជុំពិគ្រោះយោបល់ស្ដីពីការបែងចែកផលប្រយោជន៍រេដបូកដំណាក់កាលទី២ ត្រូវបានធ្វើចាប់ពីខែឧសភា ដល់មិថុនា ដើម្បីប្រមូលធាតុចូលពីសមាជិកសហគមន៍ទាំង ២០ភូមិ សម្រាប់ការៀបចំយន្តការបែងចែកផលប្រយោជន៍ដំណាក់ការទី២។ សហគមន៍ទាំង២០ភូមិបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងការអភិរក្ស ដើម្បីទទួលបាននូវថវិការដំណាក់កាលទី២ ពីការលក់ឥណទានការបូន។ ចំនួនថវិកាដែលសហគមន៍និមួយៗនឹងត្រូវទទួលបាន ផ្អែកទៅលើការវាយតម្លៃលើការចូលរួមអនុវត្តន៍ការបន្ថយការបាត់បង់គម្របព្រៃឈើនៅក្នុងសហគមន៍របស់ពួកគេក្នុងរយៈពេលមួយឆ្នាំ។ កិច្ចព្រមព្រៀងក៏មានការចូលរួមគាំទ្រពីតំណាងអជ្ញាធរឃុំ និងនាយកដែនជម្រកសត្វព្រៃកែវសីមា។

គម្រោងទេសចរណ៍ធម្មជាតិក្នុងដែនជម្រកសត្វព្រៃកែវសីមាត្រូវបានចាប់ផ្ដើមនៅឆ្នាំ ២០១២ ក្នុងភូមិសាស្ត្រភូមិអណ្ដូងក្រឡឹង។ តំបន់ទេសចរណ៍ធម្មជាតិអណ្ដូងក្រឡឹងបានទាក់ទាញភ្ញៀវទេសចរជាតិ និងអន្តរជាតិមកទស្សសត្វព្រៃសំខាន់ៗជាច្រើនប្រភេទដូចជា ស្វាកន្ទុយសប៉ាក់ខៀវពោះបង្គង់ ក្ងោក ទោចផ្កាល់លឿង ទេសភាព និងទឹកជ្រោះស្អាតៗជាដើម។ ក្រុមការងារបានពង្រឹងសមត្ថភាពសហគមន៍តាមរយ:នាំសហគមន៍ទេសចរណ៍អណ្ដូងក្រឡឹង ចំនួន ១៣នាក់ ទៅទស្សនៈកិច្ចសិក្សានៅសហគមន៍ទេសចរណ៍ ចំប៉ក់

ស្ថិតក្នុងខេត្តកំពង់ស្ពឺ ដើម្បីរៀនសូត្រ
ដកបទពិសោធន៍អំពីការអនុវត្តសហគមន៍ទេសចរណ៍នៅចំប៉ក់។

| គោលបំណងទី៤ | |
|---|---|
| សកម្មភាពទី១៖ គាំទ្រសហគមន៍តំបន់ការពារធម្មជាតិស្រែព្រះ (តំបន់ផ្ទៃរងទឹកភ្លៀងអូរប៉ោរ) និងសហគ្រាសសហគមន៍ | • សហគមន៍តំបន់ការពារធម្មជាតិស្រែ<br>ត្រូវបានគាំទ្រតាមរយៈការបង្កើតកា<br>• ការផ្តល់វគ្គបណ្តុះបណ្តាលអំពីការវាយ<br>• បង្កើតនូវកិច្ចព្រមព្រៀង ដើម្បីអាចព |
| សកម្មភាពទី២៖បង្កើតការបណ្តាក់ទុនសហគមន៍អេកូទេសចរណ៍មូលដ្ឋាន | • សហគមន៍អេកូទេសចរណ៍ត្រូវបានអ<br>• រៀបចំនូវសកម្មភាពអេកូទេសចរណ៍ |
| សកម្មភាពទី៣៖គាំទ្រដល់ការពង្រីកសកម្មភាពកសិកម្មនៅក្នុងសហគមន៍គោលដៅ | • ផ្តល់វគ្គបណ្តុះបណ្តាលស្តីពីការដាំដុះបន្លែ<br>• ផ្តល់វគ្គបណ្តុះបណ្តាល និងចងក្រងស |
| សកម្មភាពទី៤៖ផ្តល់ការគាំទ្រផ្នែកហេដ្ឋរចនាសម្ព័ន្ធ ផ្សាភ្ជាប់ជាមួយនឹងសកម្មភាពអភិរក្ស នៅក្នុងសហគមន៍គោលដៅ | • ការបែងចែកផលប្រយោជន៍រេដបូកជ<br>• រាល់ហេដ្ឋរចនាសម្ព័ន្ធគាំទ្រដោយថវិក |
| សកម្មភាពទី៥៖ការអភិវឌ្ឍគម្រោងការចិញ្ចឹមជីវិតដោយផ្អែកទៅលើអនុផលព្រៃឈើ | • ការសិក្សាវាយតម្លៃទៅលើអនុផលព្រៃ<br>• កំណត់នូវទីផ្សារ ដែលមានសក្តានុពលនៃ |
| សកម្មភាពទី៦៖ផ្សាភ្ជាប់កាបូន/យន្តការហិរញ្ញប្បទានប្រកបដោយនិរន្តរភាព ដើម្បីគាំទ្រដល់ជីវភាពរស់នៅ | • កិច្ចព្រមព្រៀងនូវការបែងចែកផលប្រ<br>• ថវិការេដបូកគាំទ្រដល់សកម្មភាពអ |
| សកម្មភាពទី៧៖គាំទ្រដល់ការអប់រំផ្នែកបរិស្ថាន និងការយល់ដឹង ក្នុងការអភិរក្ស នៅក្នុងសាលារៀនថ្នាក់មូលដ្ឋាន សហគមន៍ ។ល។ | • រៀបចំពិធីដាំកូនឈើតាមសាលារៀន<br>• ចូលរួមគាំទ្រទិវាជីវៈចម្រុះ បរិស្ថាន ដំរី |

តារាងទី 2. លទ្ធផលសម្រេចបានក្នុងការបែងចែកផលប្រយោជន៍រេដបូកសម្រាប់ការអភិវឌ្ឍន៍សហគមន៍

| លទ្ធផល | ថវិកាចំណាយ | ការបាន់ប្រមាណ ចំនួនអ្នកទទួលផល |
|---|---|---|
| ស្ពានថ្មក្រាលឈើចំនួន ០២ កន្លែង នៅភូមិពូគង់ និងភូមិអូរប្រាយ៉ុំស្រែព្រះ ស្រុកកែវសីមាត្រូវបានសាងសង់សំរាប់ជាប្រយោជន៍សហគមន៍ គម្រោងនេះត្រូវបាន អនុវត្តសម្រេច១០០ភាគរយ ។ | គម្រោងទាំងពីរចំណាយថវិកាសរុបប្រមាណ ២០៦០០ ដុល្លារ | ស្ពាននេះនឹងមានប្រជាជនបីភូមិ ឆ្លងកាត់ញឹកញាប់ ដែលជាអ្នកភូមិ សិស្សអនុវិទ្យាល័យ ប្រមាណ ២២៦ គ្រួសារ សរុប ១០៣៩ នាក់ ស្រី ៥១៣ នាក់ ។ |
| រោងសហគមន៍ចំនួន ៨ ស្ថិតនៅភូមិស្រែអ៊ី អូរអាម អូរណា ស្រែល្វី ពូហ្សាម ពូរ៉ាង ពូកេះ និងពូដោល សាងសង់សម្រេចបាន ១០០ ភាគរយ ។ | គម្រោងនេះចំណាយថវិកាសរុបចំនួន ៦៩ ៥០០ ដុល្លារ | រោងសហគមន៍ចំនួន ៨ បំរើអោយការងារ សហគមន៍ដូចជាកិច្ចប្រជុំនានា និងជាប្រយោជន៍សាធារណៈ។ អ្នកទទួលផលសរុបចំនួន ៩៦០ គ្រួសារ សរុប ៤៨០០នាក់ ស្រី ២៦០៨ នាក់ |
| អណ្តូងស្នប់ចំនួន២០អណ្តូងស្ថិតនៅភូមិស្រែអ៊ី អូរអាម អូរណា ស្រែល្វី ពូហ៊្សាម ពូរ៉ាង ពូកេះ ខ្ទង់និងពូដោល ពូចារ ស្រែព្រះ អនុតវត្តសម្រេចបាន១០០ភាគរយ ។ | គម្រោងនេះចំណាយថវិកាសរុបចំនួន ៣៤ ៧៣០ ដុល្លារ | អណ្តូងស្នប់នេះប្រើប្រាស់ដោយ សហគមន៍ស្រែអ៊ីចំនួនប្រមាណ៦៨០ គ្រួសារ ស្មើនឹង ៣០៩៧ នាក់ ស្រី ១៨៨៤ នាក់ ។ |
| បណ្តាញទឹកស្អាតខ្នាតតូចចំនួន ៤ នៅភូមិអណ្តូងក្រឡឹង ខ្ទង់ ពូហ៊្សាម ពូតាំង អនុវត្តសម្រេចបាន ១០០ភាគរយ ។ បណ្តាញទឹកនេះអាចប្រើប្រាស់បាន២១០ | គម្រោងនេះចំណាយថវិកាសរុបចំនួនសរុបចំនួន ៣៣៧០០ដុល្លារ | បណ្តាញទឹកស្អាតខ្នាតតូចមានសមត្ថភាពផ្គត់ផ្គង់គ្រួសារចំនួន ២១០ គ្រួសារ |

| លទ្ធផល | ថវិកាចំណាយ | ការប៉ាន់ប្រមាណ ចំនួនអ្នកទទួលផល |
|---|---|---|
| គ្រួសារ។ ផ្អែកលើការវាយតម្លៃ គម្រោងនេះបានដោះស្រាយបញ្ហាអនាម័យទឹកស្អាត និងកាត់បន្ថយការចំណាយទិញទឹកប្រចាំថ្ងៃរបស់សហគមន៍ទាំង២១០គ្រួសារ ។ | | |
| ផ្លូវក្រាលគ្រួសក្រហម ចំនួន២ខ្សែ ប្រវែង ២៦៤០ ម៉ែត្រ ស្ថិតនៅភូមិស្រែព្រះ និងហ្គាទី ឃុំស្រែព្រះ ស្រុកកែវសីមា អនុវត្តសម្រេចបាន ១០០ ភាគរយ ។ | គម្រោងនេះចំណាយថវិកាសរុបចំនួនសរុបចំនួន ២០៥០០ដុល្លារ | ផ្លូវនេះនឹងមានប្រជាជន២ភូមិឆ្លងកាត់ញឹកញាប់ ដែលជាអ្នកភូមិសិស្សអនុវិទ្យាល័យ ប្រមាណ៣១៩ គ្រួសារ ១៣៨៤ នាក់ ស្រី៥៧១ នាក់ ។ |
| វគ្គបណ្តុះបណ្តាលស្តីពីបច្ចេកទេសកសិកម្ម រួមមានការចិញ្ចឹមសត្វ និងបច្ចេកទេសដាំដុះដំណាំឈើហូបផ្លែ និងកសិរុក្ខកម្ម ត្រូវបានរៀបចំឡើងសំរាប់សមាជិកសហគមន៍ពីរគឺ ភូមិស្រែព្រះ និងពូចារ ដើម្បីលើកកម្ពស់ការយល់ដឹងសមាជិកសហគមន៍ ។ | គម្រោងនេះចំណាយថវិកាសរុបចំនួនសរុបចំនួន ៨៥០ ដុល្លារ | ជាលទ្ធផលវគ្គបណ្តុះបណ្តាលនេះមានអ្នកចូលរួមសរុបចំនួន ៤២នាក់ ស្រី ២៤នាក់ ដែលបានរៀបចំនៅភូមិស្រែព្រះ និងពូចារ ។ សមាជិកសហគមន៍ដែលបានចូលរួមវគ្គនឹងប្រើចំណេះដឹងនេះទៅអនុវត្ត និងកែប្រែការអនុវត្តរបស់អោយស្របតាមបច្ចេកទេស ទទួលបានផលខ្ពស់ជាងមុន ។ |

រូបភាពទី 1. ហេដ្ឋារចនាសម្ព័ន្ធសហគមន៍ ដែលគាំទ្រដោយថវិការេដបូកសម្រាប់ការអភិវឌ្ឍន៍សហគមន៍












## ២.២.កិច្ចអន្តរាគមន៍គាំទ្រ

ក្រុមសកម្មភាពដ៏ទៃទៀតមិនទាក់ទងដោយផ្ទាល់ទៅនឹងការគំរាមកំហែងជាក់លាក់ ប៉ុន្តែវាបង្កើតលក្ខខណ្ឌសម្រាប់ការអនុវត្តនូវក្រុមសកម្មភាពទាំងបួនខាងលើ។ កម្មវិធីតាមដាន សិក្សាស្រាវជ្រាវ គឺជាការចាំបាច់

ដើម្បីតាមដាននូវភាពជោគជ័យក្នុងការគ្រប់គ្រងគម្រោង កំណត់ភាពទន់ខ្សោយ និងប្រាស្រ័យទាក់ទងជាមួយអ្នកពាក់ព័ន្ធនៅក្នុងប្រទេស។ បន្ថែមពីនេះទៀតជាការចាំបាច់ ដើម្បីធានាឱ្យបាននូវរបាយការណ៍ពេញលេញអនុលោមទៅតាមបទដ្ឋាន VCS និងតម្រូវការ CCB បានផងដែរ។ ជាក់ស្តែង ប្រសិទ្ធិភាពរដ្ឋបាល និងការកសាងសមត្ថភាពបុគ្គលិកគឺមានសារៈសំខាន់ណាស់។ ប្រសិទ្ធិភាពនៃការតៀងគរថវិការ រួមទាំងរដ្ឋបាលហិរញ្ញវត្ថុនៃគម្រោងរេដបូក មានសារៈសំខាន់ផងដែរសម្រាប់ជាសេណារីយ៉ូគោលសម្រាប់គម្រោងនេះ ដោយសន្មត់ថាម្ចាស់ជំនួយនឹងបន្តការគាំទ្រនូវសកម្មភាពជាក់លាក់មួយចំនួនតាមរយៈ មូលនិធិដែលមិនមែនបានមកពីការលក់កាបោន។

**គោលបំណង # ៥៖ ការប្រមូលព័ត៌មានអំពីបំរែបំរួលអេកូឡូស៊ី និងសង្គមរយៈពេលវែង**

សកម្មភាពការត្រួតពិនិត្យ និងការស្រាវជ្រាវដែលកំពុងអនុវត្តនៅដែនជម្រកសត្វព្រៃកែវសីមា ធ្វើឱ្យតំបន់ទេសភាពមួយនេះជាកន្លែងការសិក្សាដ៏សំខាន់មួយក្នុងតំបន់អាស៊ីអាគ្នេយ៍។ អង្គការ WCS បន្តរក្សានូវការខំប្រឹងប្រែងប្រមូលទិន្នន័យរយៈពេលវែង ។

| គោលបំណងទី៥ | សកម្មភាពសំខាន់ៗ | ស្ថានភាព |
|---|---|---|
| សកម្មភាពទី១៖ការតាមដាននិន្នាការនៃការប្រែប្រួលគម្របព្រៃឈើនៅក្នុងតំបន់ | • បង្កើតផែនទីគម្របព្រៃសម្រាប់ឆ្នាំ ២០១៨ និង ២០១៩ | បញ្ចប់ |
| | • ការត្រួតពិនិត្យ ការផ្លាស់ប្តូរ នៃរូបភាពផ្កាយរណបជាទៀងទាត់<br>• ការបោះពុម្ពនូវទិន្នន័យការបាត់បង់ព្រៃឈើជាទៀងទាត់<br>• រៀបចំរបាយការណ៍ស្តីពីការបាត់បង់ព្រៃឈើនៅក្នុងតំបន់គម្រោងជូនអ្នកពាក់ព័ន្ធ<br>• ប្រើប្រាស់ទិន្នន័យ និងវិធីសាស្រ្តតាមដានគម្របព្រៃឈើ និងការកំណត់បែងចែកតំបន់គ្រប់គ្រង | កំពុងបន្ត |
| សកម្មភាពទី២៖ការត្រួតពិនិត្យប្រភេទសត្វសំខាន់ | • ការកត់ត្រាទៅលើការបបាញ់ខុសច្បាប់ ទីតាំងអន្ទាក់សត្វព្រៃ និងសកម្មភាពល្មើសច្បាប់ដ៏ទៃទៀតនៅក្នុងទទិន្ន័យ SMART<br>• ការអង្កេតសត្វព្រៃតាមរយៈវិធីសាស្រ្តបន្ទាត់ transect ជាប្រចាំ (២ ឆ្នាំ ម្តង)<br>• ការដាក់ Camera ស្វ័យប្រវត្តិតាមដានប្រភេសត្វ<br>• ការសិក្សាស្រាវជ្រាវ និងដោះស្រាយបញ្ហាជម្លោះរវាងសត្វ និងមនុស្សជាពិសេសសត្វដំរី | កំពុងបន្ត |
| សកម្មភាពទី៣៖ត្រួតពិនិត្យ សេដ្ឋកិច្ចសង្គម និងប្រជាសាស្រ្ត | • ការអង្កេតទៅលើតម្រូវការចាំបាច់និងប្រជាសាស្រ្ត<br>• កិច្ចប្រជុំពិភាក្សាតាមសហគមន៍ ជាប្រចាំដើម្បីប្រមូលពត៌មាន<br>• ការអង្កេតទៅលើការប្រើប្រាស់ធនធានធម្មជាតិ និងសេដ្ឋកិច្ចសហគមន៍ | កំពុងបន្ត |
| សកម្មភាពទី៤៖សម្រួលដល់ការសិក្សាស្រាវជ្រាវដែលនឹងផ្តល់ប្រយោជន៍ដល់ការគ្រប់គ្រងរបស់ដែនជម្រកសត្វព្រៃកែវសីមា | • សម្របសម្រួលការសិក្សាស្រាវជ្រាវរបស់អ្នកសិក្សាស្រាវជ្រាវមកពីសាកលវិទ្យាល័យ និងស្ថាប័នស្រាវជ្រាវ ដូចជា The School of Field Study, Nagoya University Macquarie University និង Georg-August-Universität Göttingen ជាដើម | កំពុងបន្ត |

| គោលបំណងទី៥ | សកម្មភាពសំខាន់ៗ | ស្ថានភាព |
| --- | --- | --- |
| សកម្មភាពទី៥៖ធានាឱ្យមាននូវបុគ្គលិកដែលសមត្ថភាពដែលអាចរកបាន | • ការបណ្ដុះបណ្ដាលអំពីការតាមដានតាមរយៈ Remote sensing/GIS<br>• ការបណ្ដុះបណ្ដាលអំពី SMART និង SMART Connect<br>• ការផ្ដល់ឱកាសដល់បុគ្គលិកមកចូលរួមវគ្គបណ្ដុះបណ្ដាល កិច្ចប្រជុំ និងសិក្ខាសាលាថ្នាក់ជាតិ និងក្រោមជាតិ | កំពុងបន្ត |

ការតាមដានលើការបាត់បង់ព្រៃឈើ ត្រូវបានប្រើប្រាស់រូបភាពតាមផ្កាយរណប និងការចុះយកពត៍មានដល់ទីកន្លែងជាក់ស្ដែង របស់ក្រុមល្បាតនៅតាមស្នាក់ការនិមួយៗ។ ពត៌មានតាមផ្កាយរណបគឺប្រើប្រាស់សម្រាប់គាំទ្រការតាមដានការប្រែប្រួលការប្រើប្រាស់ដី ការផ្លាស់ប្ដូរស្ថានភាពព្រៃ។ SMART ជាកម្មវិធីសម្រាប់ប្រមូលពត៍មានពីសកម្មភាពដែលបានកើតឡើងនៅទីវាល ទាក់ទងនិងការល្បាត និងការតាមដានជីវៈចម្រុះ ជាពិសេស ក្រុមការងារល្បាត និងក្រុមតាមដានជីវៈចម្រុះ បានប្រើប្រាប់កម្មវិធី SMART ក្នុងដែនជម្រកសត្វព្រៃកែវសីមា។ វគ្គបណ្ដុះបណ្ដាលអំពីការប្រមូលទិន្នន័យតាមរយៈ SMART ក៏បានបានធ្វើឡើង ទៅដល់បុគ្គលិកនិងក្រុមមន្ត្រីអនុវត្តច្បាប់នៅដែនជម្រកសត្វព្រៃកែវសីមា។

ក្រុមការងារបានបណ្ដុះបណ្ដាលដល់សហគមន៍ភូមិចំនួនបីភូមិ មានភូមិស្រែអណ្ដោល ភូមិស្រែខ្ទង់ និងភូមិរយ៉ង ពីការស្វែងរកសំបុកសត្វ និងការការពារសំបុកសត្វនៅក្នុងព្រៃសហគមន៍ ការបណ្ដុះបណ្ដាលនេះដើម្បីអោយពួកគាតបាន ស្គាល់ ចាប់អារម្មណ៍ នឹងសហការចូលរួមការពារក្នុងរដូវពងកូនរបស់វា។

ក្រុមការងារបានធ្វើការសម្របសម្រួលណែនាំដល់សហគមន៍អោយយល់អំពីបញ្ហាសត្វព្រៃ និងសារៈសំខាន់នៃការការពារសត្វព្រៃ រួមទាំងអប់រំអោយឈប់កាប់បំផ្លាញព្រៃឈើជាទីជម្រករបស់សត្វព្រៃផងដែរ។ ក្រុមការងារបានផ្ដល់ឧបករណ៍ការពារសំរាប់ដេញសត្វដំរីដល់ពួកគាត់មានដូចជា ឧបករណ៍បំពងសំឡេង និងពិលបំភ្លឺ (Spot light) ហើយបានធ្វើការបណ្ដុះបណ្ដាលដល់ពួកគាត់អោយចេះប្រើប្រាស់ឧបករណ៍នេះ ដើម្បីការពារ ឬដេញសត្វព្រៃដំណាំពេលសត្វព្រៃដំរីចូលមកក្នុងចំការស៊ីដំណាំរបស់ពួកគាត់។



រូបទី **12 ការដាក់ Camera ស្វ័យប្រវត្តិតាមដានប្រភេសត្វព្រៃនៅក្នុងដែនជម្រក**

## គោលបំណងទី៦៖ ប្រសិទ្ធិភាពរដ្ឋបាល គណនេយ្យ និងនីតិវិធីទាក់ទងនឹងការរៀបចំភស្តុភារ

ដើម្បីជួយសម្រួលដល់ប្រតិបត្តិការនៃគម្រោង នីតិវិធីប្រព័ន្ធរដ្ឋបាល និងគណនេយ្យត្រូវបានបង្កើតឡើងក្នុងគោលបំណងដើម្បីផ្តល់នូវការគ្រប់គ្រងប្រកបដោយប្រសិទ្ធិភាពនៅក្នុងទីតាំងគម្រោង។
ការគ្រប់គ្រងហិរញ្ញវត្ថុបឋមដែលផ្តល់ដោយការិយាល័យកណ្តាលរបស់អង្គការសមាគមន៍អភិរក្សសត្វព្រៃ (WCS) កម្ពុជា។ ជាងនេះទៅទៀត ក៏មានបុគ្គលិករដ្ឋបាល និងហិរញ្ញវត្ថុដែលមានមូលដ្ឋានក្នុងតំបន់គម្រោង ផងដែរដើម្បីគាំទ្រដល់ប្រតិបត្តិការនេះ។

| គោលបំណងទី៦ | សកម្មភាពសំខាន់ៗ | ស្ថានភាព |
|---|---|---|
| សកម្មភាពទី១៖<br>ការវាយតម្លៃនិងការផ្តល់មតិជាទៀងទាត់<br>ទៅលើសមត្ថភាព<br>ប្រសិទ្ធិភាព<br>របស់បុគ្គលិកនិងតម្រូវការ<br>នៃការបណ្តុះបណ្តាល | • កិច្ចប្រជុំប្រចាំខែ<br>និងប្រចាំឆ្នាំជាមួយបុគ្គលិកជាទៀងទាត់<br>ដើម្បីប្រមូលមតិយោបល់<br>និងបង្កើនប្រសិទ្ធិភាពការងារ | កំពុងបន្ត |
| សកម្មភាពទី២៖ការបង្កើត<br>និងការរក្សាប្រព័ន្ធគ្រប់គ្រង<br>រដ្ឋបាល<br>និងគណនេយ្យអោយមានប្រសិទ្ធិភាព | • ផែនការការគ្រប់គ្រងដែលមានភាពបត់បែន<br>• ផែនការប្រចាំឆ្នាំ<br>• កិច្ចប្រជុំប្រចាំខែ<br>• ប្រព័ន្ធខាងភស្តុភារត្រូវបានបង្កើតតាមដែលត្រូវការ | កំពុងបន្ត |

**គោលបំណងរងទី៧៖សុវត្ថិភាពហិរញ្ញវត្ថុរយៈពេលវែង**
**សកម្មភាពសំខាន់នៅក្រោមគោលបំណងរងទី៧៖**

របាយការណ៍អនុវត្តគម្រោងសម្រាប់ធ្វើការផ្ទៀងផ្ទាត់លើកទីពន្ធូវគម្រោងរេដបូកកែវសីមា ដែលត្រូវបានវាយតម្លៃដោយក្រុមហ៊ុនឯករាជ្យ ក្នុងការវាយតម្លៃគម្រោងរេដបូកសីមាទៅតាមស្តង់ដា VCS និង CCBA ដើម្បីទទួលបានូវឥណទានកាបូនសម្រាប់ឆ្នាំ ២០១៩ ផ្តល់អោយទៅក្រុមហ៊ុន ទៅតាមកិច្ចព្រមព្រៀងទិញលក់ឥណទានកាបូនរវាងរាជរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុនដែលបានទិញកាលពីឆ្នាំ ២០១៦។

| គោលបំណងទី៧ | សកម្មភាពសំខាន់ៗ | ស្ថានភាព |
|---|---|---|
| សកម្មភាពទី១៖អភិវឌ្ឍ<br>និងអនុវត្តន៍ គម្រោងរេដ<br>)REDD+) | • ការផ្ទៀងផ្ទាត់គម្រោងរេដបូកលើទី២ (2016-2017) ត្រូវបានបញ្ចប់<br>• រៀបចំដំណើរការផ្ទៀងផ្ទាត់គម្រោងរេដបូកលើទី៣(២០១៨-២០១៩)<br>• ការស្វែងរកទីផ្សារនៃឥណទានកាបូនគម្រោង និងភាពជាដៃគូជាមួយភ្នាក់ងារលក់ឥណទានកាបូន<br>• សរុបចំណូលទទួលបានប្រហែល ៥០០ ០០០ ដុល្លាសម្រាប់ឆ្នាំ ២០១៨ និង ២០១៩ | កំពុងបន្ត |
| សកម្មភាពទី២៖បន្តទទួលជំនួយពីដៃគូម្ចាស់ជំនួយយ៉ាងទូលាយ | • ស្វែងរក<br>និងដាក់សំណើរគម្រោងទៅម្ចាស់ជំនួយ<br>ដូចជា USAID ADB និង GEF ជាដើម | កំពុងបន្ត |
| សកម្មភាពទី៣៖បង្កើនការប្រើប្រាស់មូលនិធិអភិវឌ្ឍន៍ឃុំសម្រាប់សកម្មភាពរបស់គម្រោង | • ចូលរួមក្នុងកិច្ចប្រជុំផែនការវិនិយោគឃុំ<br>និងដាក់បញ្ចូលផែនការសកម្មភាពគម្រោង<br>ចូលទៅក្នុងផែនការវិនិយោគឃុំនីមួយៗ | កំពុងបន្ត |

# ៣. ស្ថានភាពផ្នែកច្បាប់

## ៣.១. ការអនុលោមទៅតាមច្បាប់ និង សិទ្ធិកាន់កាប់ដីធ្លី

### ៣.១.១ ភស្តុតាងនៃការអនុម័ត្រសម្រាប់គម្រោង

គម្រោងរេដបូកដែនជម្រកសត្វព្រៃកែវសីមាគឺជាគម្រោងគំរូដំបូងបង្អស់របស់ប្រទេស ដែលត្រូវបានចងក្រងជាពិសេសដូច្នោះ ដែលរួមបញ្ចូលនៅក្នុងផែនទីបង្ហាញផ្លូវរេដបូកជាតិរបស់កម្ពុជា(RGC 2010)។ វាជាភស្តុតាងដែលបង្ហាញថាវាត្រូវបានយល់ព្រមពីអាជ្ញាធរផ្លូវការ ដែលគម្រោងត្រូវបានត្រូវបានទទួលការអនុញ្ញាតពីអាជ្ញាធរប្រពៃណីសមស្រប ត្រូវបានកំណត់នៅក្នុងមាតិកា ៣.៧។

### ៣.១.២ បញ្ជីច្បាប់ដែលពាក់ព័ន្ធ

គម្រោងងនេះត្រូវបានអនុលោមតាមច្បាប់ជាមួយនិងច្បាប់ដែលពាក់ព័ន្ធ,គោលនយោបាយដែលពាក់ព័ន្ធនិងបទប្បញ្ញត្តិ។

#### ៣.១.២.១ ច្បាប់ជាតិ

១. ច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាក្រកម្ពុជា (១៩៩៣)
២. ច្បាប់ភូមិបាល (២០០១)
៣. ច្បាប់ព្រៃឈើ (២០០២)
៤. ច្បាប់ការងារ (១៩៩៧)
៥. អនុក្រឹត្យលេខ១៤៦ លើសម្បទានដីសេដ្ឋកិច្ច (២០០៥)
៦. អនុក្រឹត្យលេខ ១១៨ លើកាគ្រប់គ្រងដីរដ្ឋ
៧. អនុក្រឹត្យលេខ ៨៣ ស្តីពីនីតិវិធីចុះបញ្ជីដីរបស់សហគមន៏ជនជាតិដើមភាគតិច
៨.អនុក្រឹត្យលេខ ១៤៣ ស្តីពីការបង្កើតតំបន់ព្រៃការពារសីមា (២០០៩)
៩. អនុក្រឹត្យលេខ ៨៣ ស្តីពីការបង្កើតដែនជម្រកសត្វព្រៃកែវសីមា (២០១៦)

#### ៣.១.២.២ ច្បាប់និងបទប្បញ្ញត្តិក្នុងតំបន់

១. គោលនយោបាយព្រៃឈើ (២០០២)
២.សេចក្តីប្រកាសលើការបង្កើតតំបន់អភិរក្សចម្រុះសីមា លើព្រៃសម្បទានក្រុមហ៊ុនសំលីងក្នុងខេត្តមណ្ឌលគីរីនិងក្រចេះ(២០០២។)
៣. ស.ជ.ណ លេខ៦៩៩ លើការកំណត់របស់រដ្ឋបាលព្រៃឈើដែលជាតំណាងរបស់រាជរដ្ឋភិបាលនៃប្រទេសកម្ពុជាដើម្បីប្រតិបត្តិការលក់កាបូនព្រៃឈើកម្ពុជាដោយមានការពិគ្រោះយោបល់ជាមួយ TWG-F&E (ឆ្នាំ២០០៨)។
៤. កម្មវិធីព្រៃឈើថ្នាក់ជាតិ ២០១០-២០២៩ (២០១០)
៥. ផែនទីផ្លូវរេដបូកជាតិកម្ពុជា(២០១១)
៦. បទបញ្ជា ០០១ (២០១២) លើការផ្តល់កម្មសិទ្ធិដីលើតំបន់ដីដែលមានជម្លោះ។

### ៣.១.៣ ការអនុលោមទៅតាមច្បាប់ការងារ

បុគ្គលិកនៃទីភ្នាក់ងាររដ្ឋាភិបាល រួមទាំងក្រសួងបរិស្ថានគឺត្រូវបានគ្របដណ្តប់ដោយលក្ខខណ្ឌការងាររបស់ក្រសួងរបស់គេនីមួយៗ។ទាំងនេះអាចត្រូវបានសន្មត់ថាការប្រកាន់ខ្ជាប់ទៅនឹងច្បាប់ និងលក្ខខណ្ឌរបស់រដ្ឋាភិបាល នឹងបុគ្គលិករដ្ឋាភិបាលត្រូវបានជូនដំណឹងអំពីសិទ្ធិ និងការទទួលខុសត្រូវរបស់ពួកគេតាមរយៈទម្រង់និតិវិធីរបស់បុគ្គលិករដ្ឋាភិបាល។

ចំពោះបុគ្គលិកដៃគូអង្គការក្រៅរដ្ឋាភិបាលសិទ្ធិនឹងការទទួលខុសត្រូវរបស់និយោជិក និងនិយោជកបានគ្រប់គ្រងដោយច្បាប់ហើយលើសពីនេះទៅទៀតគឺដោយកិច្ចសន្យាការងារ និងដោយគោលនយោបាយ និងបទបញ្ញផ្ទៃក្នុងរបស់អង្គការសមាគមន៏អភិរក្សសត្វព្រៃ។ រាល់កិច្ចប្រជុំគោលនយោបាយទាំងនេះ ឬក៏ តម្រូវការដ៏ច្រើនលើសលុបនៃច្បាប់និងបទបញ្ជ គឺត្រូវគ្របដណ្តប់ដោយសិទ្ធិលក្ខខណ្ឌបុគ្គលិក។ រាល់បុគ្គលិកទាំងអស់គឺត្រូវបានឲ្យថតចម្លងកិច្ចសន្យាការងាររបស់ពួកគេ ដែលបង្ហាញពីសិទ្ធិរបស់ពួកគេ

និងផ្តោតទៅលើឯកសារពាក់ព័ន្ធដទៃទៀត។សៀវភៅក្រមគោលនយោបាយមួយកំពុងដំណើរការលើបទបញ្ញ និងនិតិវិធីតំបន់បណ្តាញប្រត្តិបត្តិការត្រូវបានចែកចាយដូចដែលបានធ្វើតាមទម្លាប់ទៅបុគ្គលិកថ្មីៗអំពីការចាប់ផ្តើម និងឯកសារដែលពាក់ព័ន្ធគឺមាននៅក្នុងភាសាខ្មែរនៅតាមការិយាល័យគម្រោង។

## ៣.២ ភាពជាក់ស្តែងនៃការប្រើប្រាស់សិទ្ធិ(G5)

ភាពជាក់ស្តែងសំរាប់ការប្រើប្រាស់សិទ្ធិ ស្ថិតនៅក្រោមច្បាប់ (ស្របតាមស្តង់ដា VCS កំណែទម្រង់ ៣.៣ ផ្នែកទី ៣.១១.១) សម្រាប់ដីព្រៃរបស់រដ្ឋ។

### ៣.២.១ ដីព្រៃរបស់រដ្ឋ

តំបន់គម្រោង ដែលនឹងបង្កើតគឺជាដីរដ្ឋ១០០% នៅពេលដែលថ្ងៃគម្រោងចាប់ផ្តើម ដោយលិខិតប្រគល់ដីរបស់ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ (MAFF)តាមរយៈរដ្ឋបាលព្រៃឈើ (FA)។ ដំបូងវាត្រូវបានគេកំណត់យ៉ាងជាក់លាក់ថាជាទ្រព្យសម្បត្តិព្រៃអចិន្ត្រៃក្នុងឆ្នាំ ១៩៩៤ ដែលនៅពេលនោះគេមិនចាត់ទុកជាព្រៃផ្តល់ផលទេ។វាបានបង្កើតឡើងជាលើកដំបូងជាតំបន់អភិរក្សនៅឆ្នាំ ២០០២ ដោយបទប្បញ្ញត្តិជាមួយរដ្ឋាភិបាល ('ប្រកាស') ដែលបានចុះហត្ថលេខាដោយរដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ។ស្ថានភាពនេះគឺកើតមានទន្ទឹមគ្នា ដែលតំបន់នេះត្រូវវាបានចាត់ទុកថាជាព្រៃផ្តល់ផល។ ស្ថានភាពដីនៃតំបន់ដែលត្រូវបានកំណត់យ៉ាងជាក់លាក់ក្នុងការការពារព្រៃនៅថ្ងៃទី ៤ ខែកញ្ញា ឆ្នាំ ២០០៩ ដោយមានការយល់ព្រមពីអនុក្រឹត្យ (លេខ ១៤៣, ២០០៩) ដោយគណៈរដ្ឋមន្ត្រីនិង**សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន** ដូច្នេះនេះគឺជាការលើកកម្ពស់ស្ថានភាពអភិរក្សរបស់ខ្លួន។ ការបង្កើនសកម្មភាពស្របច្បាប់តំបន់ព្រៃការពារសីមានេះ និងបានអះអាងដោយក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទតាមរយៈរដ្ឋបាលព្រៃឈើ ខណៈដែលស្ថាប័នរដ្ឋាភិបាលទទួលខុសត្រូវគ្រប់គ្រងវា។អនុក្រឹត្យនេះមានគោលបំណងចំនួនប្រាំបួនដែលត្រូវបានរាយនាមដូចខាងក្រោម:

1. ការពារអភិរក្សនិងស្តារនីតិសម្បទាធនធានហ្សែនរបស់សត្វនិងរុក្ខជាតិដែលត្រូវបានគំរាមកំហែងនៅទូទាំងពិភពលោក។
2. ការពារ និងស្តារប្រព័ន្ធអេកូឡូស៊ីដែលសំខាន់ជាជំរកសម្រាប់ទម្រង់ទាំងអស់នៃជីវចំរុះ។
3. ការចូលរួមចំណែកក្នុងការការពារ និងការអភិរក្សដើម្បីបំពេញតាមគោលដៅនៃផែនការអភិវឌ្ឍន៍សហស្សវត្សរ៍ជាតិនៃរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា និងរក្សាបាននូវគម្របព្រៃឈើ។
4.អភិរក្សវប្បធម៌នឹងប្រពៃណីរបស់ជនជាតិដើមភាគតិចនិងសហគមន៍មូលដ្ឋានដែលជាកន្លែងដែលពួកគេកំពុងរស់នៅក្នុងតំបន់ព្រៃការពារ។
5.ការពារធនធានធម្មជាតិដែលសហគមន៍ទាំងនេះពឹងផ្អែកលើសម្រាប់ជីវភាពរស់នៅរបស់ពួកគេនិងដើម្បីអនុវត្តកម្មវិធីកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។
6.ការរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមប្រកបដោយនិរន្តរភាពតាមរយៈការចូលរួមក្នុងការគ្រប់គ្រងធនធានប្រមូលផលព្រៃឈើដោយសហគមន៍ក្នុងតំបន់ការអភិវឌ្ឍអេកូទេសចរណ៍និងសកម្មភាពស្រដៀងគ្នាផ្សេងទៀតដែលមានផលប៉ះពាល់តិចតួចទៅនឹងធនធានជីវសាស្ត្រព្រៃឈើនិងសត្វព្រៃ។
7. ការពារកាបូននៅក្នុងរុក្ខជាតិដើម្បីកាត់បន្ថយកាបូនឌីអុកស៊ីត (ឧស្ម័ន$CO_2$) ដែលបំភាយទៅក្នុងបរិយាកាស។
8. រក្សាសំណឹកដី ដើម្បីការពារជីជាតិដីរក្សាស្ថេរភាពនិងគុណភាពនៃប្រភពទឹក។
9. គាំទ្រសកម្មភាពផ្សេងៗទៀតរួមទាំងការស្រាវជ្រាវបច្ចេកទេស និងវិទ្យាសាស្ត្រ អប់រំបណ្តុះបណ្តាល ការអភិវឌ្ឍន៍សហគមន៍ និងការសិក្សាពីបរិស្ថានដែលត្រូវបានទាក់ទងទៅនឹងការអភិវឌ្ឍនិងការអភិរក្សប្រកបដោយនិរន្តរភាពនៅថ្នាក់មូលដ្ឋានថ្នាក់ជាតិនិងអន្តរជាតិ។

អនុក្រឹតនេះគឺជាភស្តុតាងចាំបាច់នៃកម្មសិទ្ធិ/សិទ្ធិប្រើប្រាស់សម្រាប់រដ្ឋបាលព្រៃឈើក្នុងការអភិវឌ្ឍគ្រប់គ្រងគម្រោងកម្មវិធី

រេដបូកព្រៃការពារសីមាក្នុងនាមជារាជរដ្ឋាភិបាលកម្ពុជា ដែលជាដីត្រូវរាជរដ្ឋាភិបាលគ្រប់គ្រងយ៉ាងច្បាស់លាស់។ ដូចគ្នានេះផងដែរក្នុងគោលបំណងទី៧ បានផ្តល់ឱ្យរដ្ឋបាលព្រៃឈើនូវលិខិតប្រគល់សិទ្ធិយ៉ាងច្បាស់លាស់ដើម្បីអនុវត្តគោលនយោបាយដើម្បីគ្រប់គ្រងតំបន់នេះសម្រាប់ការលុបបំបាត់ការ បំភាយឧស្ម័នកាបូន។ នៅខែមេសា ឆ្នាំ២០១៦ តំបន់គម្រោងត្រូវបានផ្ទេរការគ្រប់គ្រងឲ្យនូវក្រោម ក្រសួងបរិស្ថាន (MoE) ដោយអនុក្រឹត្យលេខ ៦៩។ ព្រៃការពារសីមាត្រូវបានផ្តូរឈ្មោះទៅជាដែនជម្រកសត្វព្រៃកែវសីមា ដោយអនុក្រឹត្យលេខ៨៣ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ ២០១៦ ដែលមានគោលបំណងចំនួន៣៖

១. ធានាការពារជំរកសត្វព្រៃនិងប្រព័ន្ធអេកូឡូស៊ីនិងដើម្បីធានាឲ្យបាននូវលក្ខខណ្ឌចាំបាច់សម្រាប់ប្រភេទនៃសត្វរុក្ខជាតិនិង ជីវចម្រុះ ណាមួយ

២. ផ្តល់នូវផលិតផល និងសេវាកម្មធម្មជាតិសម្រាប់ការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព

៣. លើកកម្ពស់ការចូលរួមនិងការរួមចំណែករបស់សហគមន៍មូលដ្ឋានក្នុងការគ្រប់គ្រងតំបន់ការពារនិងអភិរក្សជីវចម្រុះនិងធនធានធម្មជាតិនៅក្នុងតំបន់នេះ។

### ៣.២.១.១ ការកំណត់លើសិទ្ធទទួលបានព្រៃដើម្បីផ្ទេរទៅប័ណ្ណកម្មសិទ្ធិសមូហភាព

ផ្នែកខ្លះនៃដែនជម្រកសត្វព្រៃកែវសីមា ត្រូវបានគេអះអាងថាគឺជាដីកម្មសិទ្ធរបស់សហគមន៏ជនជាតិដើមភាគតិច តាមច្បាប់ភូមិបាលនៃមាត្រា ២៣ -២៨ ឬមានសិទ្ធិទទួលបានសក្តានុពល។ នៅក្នុងតំបន់ជាម្ចាស់កម្មសិទ្ធិ ជាធម្មតាត្រូវបានផ្ទេរដោយដំណើរការនៃច្បាប់ទៅឲ្យសហគមន៍និងដីដែលកំណត់ជាផ្នែកមួយនៃសម្បត្តិព្រៃឈើអចិន្ត្រៃយ៍, ទោះបីជាក្បាលដីមួយចំនួននៅតែមានលើបញ្ជីដីធ្លីដែលជាដីរដ្ឋនិងសហគមន៍មានសិទ្ធិលក់ដីទាំងនេះ។ការចេញប័ណ្ណកម្មសិទ្ធទាំងនេះគឺជាយុទ្ធសាស្ត្រស្នូលមួយនៃគម្រោង ព្រោះវានឹងជួយឱ្យមានស្ថេរភាពអនុញ្ញាតឲ្យការប្រើប្រាស់ដីនិងការពារសិទ្ធិសហគមន៍និងតំបន់ដែលទទួលបានកម្មសិទ្ធិភាគច្រើនអាចទទួលការចុះប័ណ្ណកម្មសិទ្ធិក្នុងមូលដ្ឋាន។ ភូមិជាច្រើនប័ណ្ណកម្មសិទ្ធិត្រូវបានចេញក្នុងអំឡុងឆ្នាំ ២០១២ -២០១៣ ។ ភាពមិនប្រាកដប្រជាដែលបានផ្តល់លើសិទ្ធិកាបូននៅក្នុងតំបន់ទាំងនេះ, និងការលំបាកនៃការបង្កើត កិច្ចព្រមព្រៀងVCS ៦០ ឆ្នាំជាកិច្ចព្រមព្រៀង "មិនអាចបដិសេធបាន" លើសិទ្ធិនៃការប្រើប្រាស់ តំបន់ទាំងនេះមុនពេលការបែងចែកផលការរៀបចំនិងចំណូលរយៈពេលវែង, ដែលតំបន់ទាំងនេះ ត្រូវបានដកចេញពីតំបន់គម្រោង។ តំបន់ទាំងនោះត្រូវបានដាក់ជាតំបន់លិចធ្លាយនៃគម្រោង និងនៅតែផ្តោតលើរាល់សកម្មភាព ដែលនឹងអនុវត្ត ប៉ុន្តែមិនរួមចំណែកទៅលើការទទួលបាននូវឥណទានកាបូននោះ។

### ៣.២.២ ក្រុមហ៊ុនព្រៃសម្បទានសាមលីងអន្តរជាតិ

ដូចដែលបានកត់សម្គាល់ទុកក្នុងផ្នែកទី១.៣ គម្រោងស្ថិតក្នុងតំបន់ក្រុមហ៊ុនព្រៃសម្បទានអន្តរជាតិសំលីងត្រូវបានផ្តល់អោយក្នុងឆ្នាំ១៩៩៤។ ព្រៃសម្បទាននេះត្រូវបានបញ្ឈប់លែងឱ្យប្រតិបត្តិការឈើនៅក្នុងឆ្នាំ ១៩៩៩ និងមិនរំពឹងទុកថានឹងមានដំណើរការឡើងវិញនៅក្នុងប្រទេសនេះឡើយ។

ហេតុដូច្នេះហើយបានជាមិនមានហានិភ័យនៃការបោកបញ្ឆោតបាននៃការកាប់ឈើពាណិជ្ជកម្មនៅតំបន់ របស់ក្រុមហ៊ុនសាមលីង។ នេះត្រូវបានពង្រឹងនៅឆ្នាំ ២០០៩ អនុក្រឹត្យប្រកាសពី ដែនជម្រកសត្វព្រៃកែវសីមាដែល តំបន់ទាំងមូលជាព្រៃការពារ ដែលជាប្រភេទដីដែលមិនអនុញ្ញាតឱ្យមានប្រតិបត្តិការសម្បទានឈើឡើយ។ អត្ថិភាពនៃកិច្ចសន្យាសម្បទាននោះគឺមិនត្រូវបានគេជឿថាអាចផ្តល់សិទ្ធិអោយក្រុមហ៊ុនអន្តរជាតិសាមលីង

មានតួនាទីណាមួយនៅក្នុងការគ្រប់គ្រងឬការបែងចែកផលការរៀបចំគម្រោងរេដកែវសីមាទេ។

## ៣.៧ ការគោរពសិទ្ធិនិងគ្មានការស្ម័គ្រចិត្តក្នុងការផ្លាស់ប្តូរទីតាំង (G5)

### ៣.៧.១ សេរីភាព ការផ្តល់ព័តមានជាមុន និងការយល់ព្រម (FPIC)

ការយល់ព្រមលើរាល់សកម្មភាពរេដបូកទាមទារពីសហគមន៍ដែលប្រើប្រាស់ដីធ្លីប្រសិនបើសកម្មភាពប៉ះពាល់ដល់ពួកគេ។ លើសពីនេះទៅទៀតក្រោមលក្ខខណ្ឌVCS និង CCBA សិទ្ធិជាម្ចាស់កាបូនសម្រាប់ដីមួយចំនែកណាមួយនោះត្រូវតែមានការយល់ព្រមលក់ជាផ្លូវការនៃ ឥណទានចេញពីកម្មសិទ្ធិទាំងនេះ។ តំបន់គម្រោងគឺជាដីសាធារណ:របស់រដ្ឋ១០០%នៅលើចលនវត្ថុព្រៃឈើអចិន្ត្រៃយ៍ដែលនាំឲ្យស្ថានការណ៏មានលក្ខណ:សាមញ្ញដែលសិទ្ធិទៅលើទ្រព្យសម្បត្តិកាបូនទាំងអស់របស់រដ្ឋដែលជាការសម្រេចចិត្ត ដំបូងបំផុត។ ទោះយ៉ាងណាសហគមន៍មានសិទ្ធិប្រពៃណីដែលត្រូវបានទទួលស្គាល់នៅក្នុងច្បាប់ក្នុងការប្រើប្រាស់ដីសាធារណ:របស់រដ្ឋ។ ហេតុនេះហើយបានជាមានសរសេរជាលាយលក្ខអក្សយ៉ាងច្បាស់លាស់ពីសហគមន៍អំពីការយល់ព្រម ដែលបានទទួលពីសហគមន៍ទាំង ២០ ដែលកំពុងចូលរួមក្នុងគម្រោង។ នេះបង្ហាញថារដ្ឋាភិបាលមានការប្តេចដ្ឋាចិត្ត ដោយចាត់ទុកសហគមន៍ជាអ្នកចូលរួមគម្រោងយ៉ាងសកម្មនិងអ្នកមានសិទ្ធិកាន់កាប់ផងដែរ។

ការយល់ព្រមត្រូវបានទទួលបានតាមរយ:ដំណើរការដែលបានចាប់ផ្តើមនៅក្នុងដំណាក់កាលដំបូងនៃគម្រោងនេះ មុនជំហានណាមួយដើម្បីផ្តល់សុពលភាពគម្រោងនេះ ឬការលក់នូវឥណទានកាបូននៅក្នុងគម្រោង។ ការយល់ព្រមនេះត្រូវបានផ្តល់ដោយសេរីនិងដោយផ្អែកលើកិច្ចខិតខំប្រឹងប្រែងយ៉ាងទូលំទូលាយដើម្បីធានាឱ្យបានហត្ថលេខីត្រូវបានគេជូនដំណឹង, ដូចបានរៀបរាប់ក្នុងផ្នែកទី 2.7។ ការរៀបចំនូវកិច្ចព្រមព្រៀងការយល់ព្រមសហគមន៍ (អាចស្នើសុំបាន) មានគោលបំណងដើម្បីធ្វើតាមការអនុវត្តន៍ល្អបំផុតនៅក្នុងទិដ្ឋភាពរួមទាំងមូល។ ក្រុមការងារគម្រោងជឿថាវាស្របទៅនឹងតម្រូវការនៃច្បាប់ជាតិកម្ពុជានិងស្របតាម តម្រូវការ VCS និង CCB និងសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច (UNDRIP; 2007)។ វារៀប រាប់លម្អិតនៅក្នុងអ្វីដែលត្រូវបានយល់ព្រម, រយ:ពេលនៃកិច្ចព្រមព្រៀងនេះសិទ្ធិនិងការទទួលខុសត្រូវដែលបានយល់ព្រមជាបន្តបន្ទាប់។ កិច្ចព្រមព្រៀងនៃការយល់ព្រម ដែលត្រូវបានចុះហត្ថលេខាដោយតំណាងសហគមន៍ដែលសមស្របបំផុត ក៏ដូចជាមួយនឹងស្នាមផ្តិតមេដៃពីគ្រួសារភាគច្រើនបំផុតនៅក្នុងភូមិនីមួយ។ ដំណើរការនៃការទទួលការយល់ព្រមនេះគឺជាផ្នែកមួយនៃដំណើរការពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយភាគីពាក់ព័ន្ធដែលត្រូវបានរៀបរាប់ក្នុងផ្នែកទី 2.7 ។

### ៣.៧.២ ផ្លាស់ប្តូរទីលំនៅដោយមិនមានការស្ម័គ្រចិត្ត

គម្រោងនេះរំពឹងថាគ្មានផ្លាស់ប្តូរទីលំដោយមិនមានការស្ម័គ្រចិត្ត ប្រជាជនដែលរស់នៅដោយស្របច្បាប់នៃនៅក្នុងតំបន់មិនថាទាំងដីលំនៅដ្ឋានឬដីកសិកម្មឡើយ។ ទោះយ៉ាងណាក៏ដោយការតាំងលំនៅខុសច្បាប់ឬរំលោភយកដីដើម្បីប៉ុនប៉ងកាន់កាប់ដីរបស់សហគមន៍ ឬ រដ្ឋអាចនឹងត្រូវបានចាប់ខ្លួនដោយអាជ្ញាធរពាក់ព័ន្ធនិងបានយកចេញដោយគ្មានសំណងនិងអាចធ្វើទៅបានដោយការកាត់ទោសដោយយោងតាមច្បាប់។

ជាទូទៅ គម្រោងនឹងដាក់ការរឹតបន្តឹងលើការប្រើប្រាស់នៃធនធានព្រៃឈើលើសពីតម្រូវដោយច្បាប់ជាមូលដ្ឋានសម្រាប់ការអនុវត្តន៍ប្រកបដោយនិរន្តរភាព នៅក្នុងករណីជាច្រើនដែលនឹងធ្វើឱ្យប្រសើរឡើងនូវសុវត្ថិភាពនៃការដំណើរការនិងស្ថានភាពនៃធនធានទាំងនេះ។ នេះជាករណីលើកលែងមួយគឺថាគម្រោងនេះត្រូវបានរំពឹងថានឹងស្នើឱ្យមានការរឹតបន្តឹង

មួយចំនួនលើសិទ្ធិប្រើប្រាស់ជាទម្លាប់នៅក្នុងតំបន់ដែលត្រូវបានកំណត់ថាជាតំបន់ការពារតឹងរ៉ឹង (SPZs) ដែលនឹងក្លាយជាតំបន់សូន្យឬគ្មានមនុស្សរប្រើប្រាស់ត្រូវបានរចនាឡើងដើម្បីឱ្យប្រសើរឡើង ការរំពឹងទុកការរស់នៅរបស់ប្រភេទសត្វព្រៃដែលងាយរងគ្រោះបំផុត (ជាផ្នែកមួយនៃសកម្មភាព 1.2, ចំណុច 2.2) ។ ទំហំនិងទីតាំងនៃ SPZs ដែលបានស្នើឡើងនេះមិនទាន់ត្រូវបានសម្រេចនោះទេប៉ុន្តែពួកគេនឹងត្រូវបានដាក់ដើម្បីកាត់បន្ថយចំនួនអ្នកប្រើប្រាស់ព្រៃឈើរងផលប៉ះពាល់។ ការដាក់កម្រិតនៃការប្រើប្រាស់បិតនៅក្រោមនិយមន័យបទដ្ឋាន CCB នៃការ "**ផ្លាស់ប្តូរទីតាំង**" ប៉ុន្តែនេះនឹងមិនត្រូវបានកំណត់ថាជាដំណើរការដោយមិនមានការស្ម័គ្រចិត្តឡើយ។ ការកំណត់តំបន់បែបនេះនឹងត្រូវបានបន្តដោយការប្រឹក្សាយោបល់និងដំណើរការយល់ព្រមលម្អិតតាមភូមិដែលរងផលប៉ះពាល់, ការកំណត់អត្តសញ្ញាណរបស់បុគ្គលដែលរងផលប៉ះពាល់ / គ្រួសារនិងចរចាកញ្ចប់សំណងទទួលយកបានទៅវិញទៅមកនោះដែលអាចនឹងរួមបញ្ចូលប៉ុន្តែមិនត្រូវបានកំណត់ដូចជា ឱកាសការងារ, ក្នុងប្រភេទ ប្រាក់សំណង (ឧទាហរណ៍ៈការចិញ្ចឹមជីវិត) ឬសំណងផ្នែកហិរញ្ញវត្ថុ (ឧទាហរណ៍ៈ ការរកប្រាក់ចំនូលដោយការដងជ័រ) ។ ការបញ្ជាក់ថាដំណើរការនេះនឹងយល់ព្រមត្រូវបានរួមបញ្ចូលនៅក្នុងអត្ថបទនៃកិច្ចព្រមព្រៀងសហគមន៍។

ដោយសារតែមានព្រំដែននៅក្នុងតំបន់មានការស្មុគ្រស្មាញនៅក្នុងតំបន់គម្រោង វិធីសាស្រ្តសម្រាប់យោងព្រំដែនជាផ្លូវការ ដោយបុគ្គលិកល្បាតជាតម្រូវការនៃក្របខ័ណ្ឌត្រួតពិនិត្យការអនុវត្តច្បាប់។ បុគ្គលិកតាមតំបន់កំណត់តំបន់ព្រំដែនមួយនៅក្នុងតំបន់តាមរយៈ (ក) ការប្រើប្រាស់នៃពហុកោណព្រំដែនបានផ្ទុកនៅលើប្រព័ន្ធ GPS ត្រូវបានអនុវត្តនៅក្នុងតំបន់ (ខ) ការបើកមើលទីតាំងជាក់ស្តែង ដោយអ្នកសម្របសម្រួល GIS ។ វគ្គបណ្តុះបណ្តាទៀងទាត់នៅក្នុងការប្រើប្រាស់ប្រព័ន្ធ GPS និងការទទួលស្គាល់នៃព្រំដែននេះត្រូវបានផ្តល់ជូនដល់បុគ្គលិកល្បាតដើម្បីសម្របសម្រួល GIS ។ ព្រំដែនទាំងនេះក្នុងនោះរួមទាំងព្រំប្រទល់ផ្លូវការតាមសារាចរ 001 (2012), គឺអាចមើលឃើញយ៉ាងច្បាស់ក្នុងការបង្ហាញ GPS នេះ។ សម្រាប់បុគ្គលិកល្បាតប្រើផែនទីក្រដាសកូអរដោនេត្រូវបានពិនិត្យជាមួយនឹងមន្រ្តី GIS មុនពេលទៅធ្វើសកម្មភាព។ លើសពីនេះទៀតការត្រួតពិនិត្យបន្ថែមទៀតនៅក្នុងការិយាល័យត្រូវបានធ្វើឡើងដោយមានតំបន់ដែលបានប្រមូលទិន្នន័យ។ បើមានការសង្ស័យថារាល់ការទន្រ្ទានត្រូវបានកត់ត្រាដោយបុគ្គលិកល្បាតនិងបានបញ្ចូលនៅក្នុង ប្រព័ន្ធនៃការត្រួតពិនិត្យផែនទីនិងរាយការណ៍ឧបករណ៍ (SMART) ដោយធៀបទៅនឹងព្រំដែនជាផ្លូវការ (រួមទាំងបទបញ្ជា 001) ដែលអាចត្រូវបានត្រួតពិនិត្យ។

## ២.៨ សកម្មភាពខុសច្បាប់ និងអត្ថប្រយោជន៍គម្រោង (G5)

សកម្មភាពគម្រោងរួមបញ្ចូលគ្នានូវកិច្ចខិតខំប្រឹងប្រែងដើម្បីទប់ស្កាត់សកម្មភាពខុសច្បាប់( ឧទាហរណ៍ តាមរយៈការធ្វើផែនការនិងការអនុវត្តដោយផ្ទាល់) និងកិច្ចខិតខំប្រឹងប្រែងដើម្បីបង្កើនជីវភាពរស់នៅតាមរយៈការអន្តរាគមន៍ដែលមានការបញ្ជាក់យ៉ាងច្បាស់ផ្នែកច្បាប់ (ឧទាហរណ៍ ការផ្តល់ជំនួយផ្នែកកសិកម្មនៅលើដីដែលត្រូវបានចិញ្ចឹមដោយស្របច្បាប់អេកូទេសចរណ៍នៅក្នុងតំបន់ដែលមានការអនុម័តពីរដ្ឋាភិបាលជាដើម) ។ ការការពារសុវត្ថិភាពនឹងត្រូវបានដាក់នៅនឹងកន្លែងដើម្បីធានាឱ្យបាននូវគម្រោងដែលមានមូលនិធិមិនត្រូវបានប្រើដោយមិនលើកកម្ពស់សកម្មភាពខុសច្បាប់ (ឧទាហរណ៍ៈ ដោយពិនិត្យជំនួយឥតសំណងសម្រាប់គម្រោងសហគមន៍) ។

សកម្មភាពខុសច្បាប់ជាច្រើន ជំរុញការគំរាមកំហែងទៅនឹងការប្រែប្រួលអាកាសធាតុ ជីវចំរុះនិងសហគមន៍ដែលត្រូវបានដាក់ក្នុងសេណារីយ៉ូលគោល ដូច្នេះហើយគម្រោងនេះត្រូវបានរចនាឡើងឱ្យច្បាស់ដើម្បីដោះស្រាយទាំងនោះ (ចំណុច 2.2) ។ សកម្មភាពដែលនៅក្រោមអនុគោលដៅ គឺត្រូវបានរចនាឡើងទាំងអស់ដើម្បីបង្កើនការអនុវត្តច្បាប់ដោយផ្ទាល់, ជាចម្បងដោយក្រុមល្បាតដែលដឹកនាំដោយរដ្ឋាភិបាលផងក៏ដូចជាក្រុមល្បាតដែលដឹកនាំដោយសហគមន៍ និងវិធានការផ្សេងទៀតរួមបញ្ចូលទាំងការត្រួតពិនិត្យប្រចាំខែនិងប្រចាំឆ្នាំនៃកម្រិតនៃសកម្មភាពខុសច្បាប់។ អនុគោលបំណងទី ១

មានគោលបំណងដើម្បីដាក់នូវក្របខ័ណ្ឌច្បាប់និងការធ្វើផែនការដែលបានបង្អាក់សកម្មភាពខុសច្បាប់និងអនុគោលបំណងទី៣
មានគោលបំណងក្នុងការបង្កើតច្បាប់គ្រប់គ្រងនិងការកាន់កាប់ដីនិងប្រព័ន្ធគ្រប់គ្រងដីធ្លីនៅក្នុងតំបន់សហគមន៍។